ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# គោលនយោបាយ និងក្របខ័ណ្ឌ
# យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម
# ២០១៦-២០២០

តុលា ឆ្នាំ ២០១៥

ឧបត្ថម្ភដោយ:

USAID ជំនួយពីពលរដ្ឋអាមេរិក

Save the Children

Disclaimer: Printing of this policy is made possible by the generous support of the American people through the United States Agency for International Development (USAID) under Cooperative Agreement No. AID-442-A-14-00006. The contents do not necessary reflect the views of USAID or the United States Government.

# មាតិកា


**អារម្ភកថា** .......... ii

**១. សេចក្តីផ្តើម** .......... ១

**២. ក្របខ័ណ្ឌច្បាប់** .......... ២

**៣. ទិដ្ឋភាពរួមៈ យេនឌ័រនិងកសិកម្ម** .......... ៤

**៣.១.និន្នាការបច្ចុប្បន្ន និងហានិភ័យ** .......... ៥

**៣.២. ការវាយតម្លៃយេនឌ័រក្នុងវិស័យ និងអនុ-វិស័យកសិកម្ម** .......... ៧

ស្ត្រី និងអក្ខរភាព .......... ៧

តំណាងស្ត្រីនៅក្នុងរដ្ឋបាលកសិកម្ម .......... ៧

ស្ត្រី និងលទ្ធភាពទទួលបានសេវាផ្សព្វផ្សាយកសិកម្ម .......... ៨

ស្ត្រី និងការទទួលបាននូវឧបករណ៍ និងបច្ចេកវិទ្យាកសិកម្ម .......... ៨

លទ្ធភាពទទួលបានសេវាកម្មហិរញ្ញវត្ថុរបស់ស្ត្រី .......... ៩

លទ្ធភាពទទួលបានដីធ្លីរបស់ស្ត្រី .......... ១០

ការឈានចូលទីផ្សាររបស់ស្ត្រី .......... ១១

ការចូលរួមរបស់ស្ត្រីក្នុងគំនិតផ្តួចផ្តើមលើការប្រែប្រួលអាកាសធាតុ .......... ១២

បញ្ហាយេនឌ័រ និងផលិតកម្មដំណាំ .......... ១៣

បញ្ហាយេនឌ័រ និងព្រៃឈើ .......... ១៤

បញ្ហាយេនឌ័រ និងផលិតកម្មកៅស៊ូ .......... ១៥

បញ្ហាយេនឌ័រ និងផលិតកម្មសត្វ .......... ១៥

បញ្ហាយេនឌ័រ និងជលផល .......... ១៦

**៤.ទស្សនវិស័យ បេសកកម្ម និងគោលដៅរួម** .......... ១៧

**៥. គោលបំណងជាយុទ្ធសាស្ត្រ** .......... ១៨

**៦. ការអនុវត្ត** .......... ១៩

**ឧបសម្ព័ន្ធ** .......... ២២

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកថា ស្ត្រីគឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ និងសង្គមកម្ពុជាតាំងពីយូរមកហើយ។ នៅក្នុងអាណត្តិទី៥នេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានបន្តដោះស្រាយបញ្ហាវិសមភាពយេនឌ័រ និងធ្វើឲ្យល្អប្រសើរឡើងនូវស្ថានភាពស្ត្រី ដូចបានកំណត់ ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ (២០១៤-២០១៨) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) និងផែនការយុទ្ធសាស្ត្រយេនឌ័រ (នារីរតនៈ ២០១៤-២០១៨) ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានការប្តេជ្ញាខ្ពស់ ក្នុងការពន្លឿនការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវអភិក្រមថ្នាក់ជាតិទាំងនេះ និងបង្កើតឡើងនូវទិសដៅជាយុទ្ធសាស្ត្ររបស់ខ្លួន ដើម្បីសម្រេចបាននូវសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (ASDP) ២០១៤-២០១៨។

គោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម (២០១៦-២០២០) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាមូលដ្ឋានគ្រឹះសម្រាប់បង្កើតទិសដៅជាយុទ្ធសាស្ត្រនិងសកម្មភាពការងារ ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយសមធម៌។

នៅក្នុងដំណើការ នៃការរៀបចំគោលនយោបាយនិងក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ មានការពិភាក្សា កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូយ៉ាងល្អជាមួយនឹងអង្គភាពក្រោមឱវាទ ក៏ដូចជាអ្នកពាក់ព័ន្ធ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងក្រសួងកិច្ចការនារី និងដៃគូអភិវឌ្ឍន៍នានា។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះក្រុមការងារយេនឌ័រ និងកុមារ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ បុគ្គលិកគ្រប់ជាន់ថ្នាក់ និងអ្នកពាក់ព័ន្ធដែលបានចូលរួមយ៉ាងសកម្ម និងមានការប្តេជ្ញាខ្ពស់ក្នុងដំណើរការនៃការចងក្រងគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ។ គោលនយោបាយនេះ គឺជាការរួមចំណែកដ៏ទូលំទូលាយមួយ ក្នុងការដោះស្រាយបញ្ហាប្រឈមនៃវិសមភាពយេនឌ័រ ដែលនៅសេសសល់ក្នុងវិស័យកសិកម្មនៅកម្ពុជា ដើម្បីធានាឲ្យជីវិតប្រជាជនកម្ពុជា និងកូន ចៅជំនាន់ក្រោយមានភាពប្រសើរឡើង។

ក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំសូមឲ្យអង្គភាពក្រោមឱវាទក្រសួងគ្រប់លំដាប់ថ្នាក់ និងអ្នកពាក់ព័ន្ធទាំងអស់ ចូលរួមយ៉ាងពេញទំហឹង និងសហការអនុវត្តគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ ក្រោមការសម្របសម្រួលរបស់ក្រុមការងារយេនឌ័រ និងកុមារ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការអនុវត្តយ៉ាងពេញលេញនូវគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម (២០១៦-២០២០) នឹងក្លាយជាជំហានដ៏សំខាន់មួយឈានទៅសម្រេចបានសមភាពយេនឌ័រ និងការអភិវឌ្ឍកម្ពុជានាពេលអនាគត។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

# ១. សេចក្តីផ្តើម

វិស័យកសិកម្មនៅតែមានតួនាទីសំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច ធានាសមធម៌ សន្តិសុខស្បៀង និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ។ ចក្ខុវិស័យរយៈពេលវែង[១] របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺដើម្បី "រួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ធានាបាននូវភាពមានស្បៀងគ្រប់គ្រាន់និងប្រកបដោយ សុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋគ្រប់រូប តាមរយៈការធ្វើទំនើបកម្មវិស័យកសិកម្មកម្ពុជា តាមអភិក្រម ក្នុងវិសាលភាព និងល្បឿនថ្មី សំដៅជំរុញការរីកលូតលាស់សេដ្ឋកិច្ចកសិកម្ម និងការគ្រប់គ្រងនិងអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តភាព"។

គោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម បានកំណត់យ៉ាងច្បាស់លាស់ និងបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយផ្តោតទៅលើសមភាពយេនឌ័រ។ ឯកសារនេះ បានលើកឡើងពីទស្សនវិស័យ គោលដៅរួម គោលបំណងជាយុទ្ធសាស្ត្រ និងជំហានក្នុងការអនុវត្តការបញ្ជ្រាបទស្សនយេនឌ័រទៅក្នុងសកម្មភាពការងាររបស់ស្ថាប័នក្រោមឱវាទ និងអនុ-វិស័យ (កសិកម្ម ជលផល ផលិតកម្មសត្វ និងព្រៃឈើ) នៃវិស័យកសិកម្ម។ គោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ នឹងផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់បង្កើនការសម្របសម្រួលនិងប្រសិទ្ធិភាព ឆ្ពោះទៅសម្រេចបានសមភាពយេនឌ័រក្នុងវិស័យកសិកម្មនៅកម្ពុជា។ ឯកសារនេះ ផ្តោតលើការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្សផ្នែកយេនឌ័រនិងកសិកម្ម ក៏ដូចជាការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីជនបទ និងជាឧទាហរណ៍មួយនៃអភិក្រមផ្អែកលើកម្មវិធី (Programme Based Approach) ។

គោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ (២០១៦–២០២០) មានសារៈសំខាន់ណាស់ ដែលទទួលស្គាល់នូវការរួមចំណែក របស់ស្ត្រីកម្ពុជាក្នុងពលកម្មកសិកម្ម ផលិតកម្ម ការប្រមូលផល ការកែច្នៃ និងទីផ្សារ។ ឯកសារនេះ កំណត់ពីបញ្ហាប្រឈមក្នុងវិស័យពាក់ព័ន្ធ និងលើកឡើងពីលទ្ធផលជាក់លាក់តាមវិស័យ និងកំណត់សូចនាករដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនោះ។ លើសពីនេះទៅទៀត បានទទួលស្គាល់ពីការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យជលផល ផលិតកម្មសត្វ និងក្នុងការគ្រប់គ្រងធនធានព្រៃឈើ ហើយក៏បានទទួលស្គាល់ពីការពឹងផ្អែកយ៉ាងខ្លាំងលើអនុផល និងផលព្រៃឈើ ដែលជាប្រភពថាមពលសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ។ គោលនយោបាយនេះ ក៏បានទទួលស្គាល់ផងដែរថា ការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាពាក់ព័ន្ធដែលមានឥទ្ធិពលលើការងារកសិកម្ម ផលិតកម្មសត្វ ជលផល និងព្រៃឈើ ដែលបញ្ហាទាំងនេះ មិនអាចកាត់ ផ្តាច់ពីការងារយេនឌ័របានឡើយ។ ដូច្នេះ ត្រូវមានដំណោះស្រាយ ដើម្បីធានាថាការផ្តួចផ្តើមគំនិតក្នុងការកាត់បន្ថយ និងបន្សាំទៅនឹងបម្រែបម្រួលអាកាសធាតុ នឹងមានឥទ្ធិពលក្នុងការរួមចំណែកដល់ការសម្រេចបាននូវ សមភាពយេនឌ័រ ។

ការធ្វើបច្ចុប្បន្នភាព និងការបង្កើតគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ (២០១៦-២០២០) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានផ្តួចផ្តើម និងដឹកនាំដោយក្រុមការងារយេនឌ័រ និងកុមាររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយសហការជាមួយនាយកដ្ឋានផែនការ និងស្ថិតិ។

---

១.ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (ASDP) ២០១៤-២០១៨ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ដំណើរការនៃការរៀបចំគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ រួមមានការប្រជុំផ្ទៃក្នុងជាបន្តបន្ទាប់ជាមួយនឹងសមាជិកក្រុមការងារយេនឌ័រនិងកុមារ ចំនួន ១៨រូប មន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជនបង្គោលយេនឌ័រ និងកុមារ នៃមន្ទីរកសិកម្មទាំង២៥ រាជធានី-ខេត្ត ដើម្បីឆ្លុះបញ្ចាំងពីសមិទ្ធផល និងបញ្ហាប្រឈមក្នុងការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ឆ្នាំ២០០៦-២០១០ កន្លងទៅ។ ជាពិសេសកិច្ចប្រជុំត្រូវបានរៀបចំឡើងជាមួយដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធដោយមានការប្រឹក្សា និងការសម្របសម្រួលជាមួយនឹងក្រសួងកិច្ចការនារី រួមទាំងការពិនិត្យឡើងវិញនូវក្របខ័ណ្ឌច្បាប់ ឯកសារ និងគោលនយោបាយគន្លឹះទាំងឡាយ របស់រាជរដ្ឋាភិបាល សម្រាប់សមភាពយេនឌ័រ និងកសិកម្មនៅកម្ពុជា។ គោលនយោបាយនេះ ត្រូវបានចងក្រងឡើងស្របទៅនឹងផែនការយុទ្ធសាស្ត្របច្ចុប្បន្នរបស់អនុវិស័យ និងវិស័យកសិកម្ម។

ក្រុមការងារយេនឌ័រនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៥ ហើយនៅក្នុងឆ្នាំ២០០៦ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសទទួលស្គាល់គោលនយោបាយ និងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្មដំបូងគេបង្អស់។ គួរកត់សម្គាល់ថាដំណើរការធ្វើបច្ចុប្បន្នភាព និងការបង្កើតគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ត្រូវបានធ្វើឡើងក្នុងធនធានមានកម្រិតរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចជាធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ រួមទាំងសមត្ថភាពស្ថាប័នក្នុងការប្រែក្លាយគោលនយោបាយ និងយុទ្ធសាស្ត្រឲ្យទៅជាការអនុវត្តជាក់ស្តែង។ ដូច្នេះ គោលនយោបាយនេះនឹងផ្តល់ឱកាសក្នុងការបង្ហាញយ៉ាងច្បាស់ពីសារៈសំខាន់នៃគណនីភាពសម្រាប់សមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រី និងនីតិវិធីនៃការភ្ជាប់ទំនាក់ទំនងរវាងការបញ្ជ្រាបយេនឌ័រ ជាមួយនឹងគោលនយោបាយសំខាន់ៗ រួមទាំងដំណើរការធ្វើផែនការ និងការរៀបចំថវិកាសម្រាប់គ្រប់អនុវិស័យ និងអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅគ្រប់កម្រិត ។

## ២. ក្របខ័ណ្ឌច្បាប់

ឱកាស និងចំណុចចាប់ផ្តើមសម្រាប់ការអភិវឌ្ឍសមភាពយេនឌ័រក្នុងវិស័យកសិកម្ម នឹងត្រូវវាយតម្លៃក្នុងក្របខ័ណ្ឌការងារ នៃការប្តេជ្ញាចិត្តរបស់គោលនយោបាយដែលពាក់ព័ន្ធកន្លងមក និងក្របខ័ណ្ឌច្បាប់ការងាររបស់រាជរដ្ឋាភិបាលកម្ពុជា។ ការអភិវឌ្ឍជាគន្លឹះ នៅក្នុងបរិយាកាសរួមនៃគោលនយោបាយ បានគាំទ្រនិងធ្វើឲ្យលេចចេញជារូបរាងនូវរបៀប ដែលកម្ពុជាបានបោះជំហានក្នុងការដោះស្រាយបញ្ហាយេនឌ័រ និងការសម្រេចគោលដៅសមភាពយេនឌ័រ។

រាជរដ្ឋាភិបាលកម្ពុជា សម្តែងនូវការគាំទ្រយ៉ាងពេញទំហឹងក្នុងការធានាបានសមភាពយេនឌ័រ ចាប់តាំងពីមានសុខសន្តិភាពឡើងវិញមកម្ល៉េះ។ សមភាពរវាងបុរស និងស្ត្រីត្រូវបានដាក់បញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឆ្នាំ១៩៩៣។ ការប្តេជ្ញាចិត្តនេះ ក៏ត្រូវបានពង្រឹងដោយការផ្តល់សច្ចាប័នទៅលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) ក្នុងឆ្នាំ១៩៩២ និងបានចុះហត្ថលេខាទៅលើ ទម្រង់ផែនការសកម្មភាព ដែលបានឯកភាព នៅក្នុងសន្និសីទស្ត្រីពិភពលោកលើកទី៤ ក្នុងឆ្នាំ១៩៩៥ នៅទីក្រុងប៉េកាំង។ នារីរតនៈ ជាផែនការយុទ្ធសាស្ត្រដែលបង្កើតឡើងចាប់តាំងពីឆ្នាំ១៩៩៩ ដោយ

ក្រសួងកិច្ចការនារី និងជាផែនការយុទ្ធសាស្ត្រ សម្រាប់សមភាពយេនឌ័រនៅក្នុងប្រទេសកម្ពុជា។ នារីរតនៈបាន សង្កត់ធ្ងន់លើទំនាក់ទំនងយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រីគ្រប់រូបភាពនៃការអភិវឌ្ឍនៅកម្ពុជា និងធានានូវនិរន្តរភាពនៃដំណើរការអភិវឌ្ឍន៍ដែលមានការឆ្លើយតបទៅនឹងយេនឌ័រ។ ក្រសួងកិច្ចការនារី បានប្រកាសដាក់ឲ្យប្រើប្រាស់ផែនការនារីរតនៈ៤ (២០១៤-២០១៨) ក្នុងខែធ្នូ ឆ្នាំ ២០១៤ ។

មកដល់សព្វថ្ងៃនេះ សមភាពយេនឌ័រ គឺជាមូលបទស្នូលយ៉ាងសំខាន់ នៃគោលនយោបាយសេដ្ឋកិច្ចសង្គមរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងផែនការយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី៣ (២០១៤-២០១៨) និងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(NSDP) រួមទាំងកម្មវិធីជាតិរយៈពេល ១០ឆ្នាំ សម្រាប់ការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ យុទ្ធសាស្ត្រចតុកោណ បានកំណត់យ៉ាងច្បាស់ពីតម្រូវការ " ដើម្បីបន្តធ្វើឲ្យប្រសើរឡើងនូវស្ថានភាពរបស់ស្ត្រី ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមកម្ពុជា"។ ក្នុងការឆ្លើយតបនឹងការយកចិត្តទុកដាក់នេះ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការពន្លឿនភាពរីកចម្រើនលើគោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជា៣(CMDG3) (សមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រី) ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេស ទៅលើការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី។ ក្របខ័ណ្ឌការងារពន្លឿនគោលដៅអភិវឌ្ឍន៍សហសវត្ស (MAF) និងផែនការសកម្មភាពការងារ របស់កម្ពុជា (២០១៣-២០១៥) ស្តីពីការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ត្រូវបានគេរំពឹងថានឹងចូលរួមធ្វើឲ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សផ្សេងៗទៀតរបស់កម្ពុជា (CMDGs)។

យន្តការស្ថាប័នជាតិសម្រាប់ការបញ្ជ្រាបយេនឌ័រនៃកម្ពុជា រួមមានសមាសភាពសំខាន់ៗចំនួន ៤ ក្នុងក្របខ័ណ្ឌរបស់ក្រសួង៖ ក្រសួងកិច្ចការនារី (MoWA), ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី(CNCW), ក្រុមការងារបច្ចេកទេសយេនឌ័រ (TWG-G), ក្រុមការងារបញ្ជ្រាបយេនឌ័រនៃក្រសួង/ស្ថាប័នពាក់ព័ន្ធ (GMAG) និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ។

គោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានបង្កើតឡើង ដើម្បីគាំទ្រដល់ការអនុវត្តនូវគោលនយោបាយ យុទ្ធសាស្ត្រ និងយន្តការជាតិដែលបានរៀបរាប់ខាងលើ ដោយផ្តោតសំខាន់លើវិស័យកសិកម្ម។ លើសពីនេះទៅទៀត គោលនយោបាយនេះត្រូវបានលើកឡើង និងអនុលោមតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (២០១៤-២០១៨)។ គោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ក្នុងវិស័យកសិកម្ម (២០១៦-២០២០) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានគោលបំណង៣ ដើម្បីសម្រេចឲ្យបាននៅឆ្នាំ ២០២០។

**គោលបំណងទាំង ៣ រួមមាន៖**

១. លើកកម្ពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី តាមរយៈលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានទំនិញ និងសេវាកម្មសម្រាប់ការអភិវឌ្ឍកសិកម្ម និងទីផ្សារកសិកម្ម។

២. ពង្រឹងសមត្ថភាព ធនធាន និងការប្តេជ្ញាចិត្តរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធានានូវប្រសិទ្ធិភាពនៃការបញ្ជ្រាបយេនឌ័រ នៅក្នុងវិស័យកសិកម្ម។

៣. បង្កើនភាពជាតំណាង និងការចូលរួមស្មើភាពគ្នាទាំងបុរស និងស្ត្រីក្នុងវិស័យកសិកម្ម។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងអនុម័តអភិក្រមសំខាន់ៗចំនួន២ ដើម្បីសម្រេចបាននូវគោលបំណងនៃសមភាពយេនឌ័រ។ ទី១ ក្រសួងនឹងធ្វើការបញ្ជ្រាបយេនឌ័រផ្ទៃក្នុង ទៅក្នុងគ្រប់ការងារទាំងអស់។ ទី២ ក្រសួងនឹងប្តេជ្ញាចិត្តខ្ពស់ក្នុងការអភិវឌ្ឍ និងអនុវត្តគំនិតផ្តួចផ្តើមឲ្យមានសមភាពយេនឌ័រ ដែលផ្តោតជាពិសេសទៅលើស្ត្រី និងការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី។

## ៣. ទិដ្ឋភាពរួមៈ យេនឌ័រនិងកសិកម្ម

នៅប្រទេសកម្ពុជាមានប្រជាពលរដ្ឋប្រមាណ ១៤.៩ លាននាក់ក្នុងនោះ ៨២% ជាគ្រួសារដែលរស់នៅតំបន់ជនបទ[២]។ ភាគច្រើននៃគ្រួសារទាំងនោះធ្វើការងារពាក់ព័ន្ធនឹងរបរកសិកម្មពឹងផ្អែកលើដំណាំស្រូវ ការនេសាទ ការប្រមូលផលព្រៃឈើ ផលិតកម្មដំណាំ និងផលិតកម្មសត្វ។ កសិកម្មមានសារៈសំខាន់ណាស់សម្រាប់ជីវភាពរបស់អ្នកដែលមានដីស្រែតិចតួច និងស្ត្រី។ នៅក្នុងឆ្នាំ ២០១៤ កសិកម្មរួមចំណែក ២៨.៧% នៃផលិតផលក្នុងស្រុកសរុប[៣]។ វិស័យនេះជាប្រភពយ៉ាងសំខាន់ក្នុងការផ្តល់ការងារដល់បុរស និងស្ត្រីជាច្រើននាក់ (ស្ត្រី៧៥%) ដែលពាក់ព័ន្ធជាចម្បងក្នុងផលិតកម្មសម្រាប់បំពេញតែសេចក្តីត្រូវការក្នុងគ្រួសារ នៅលើដីស្រែតូចៗ[៤]។ ភាគច្រើននៃស្ត្រីជនបទនៅកម្ពុជាធ្វើការងារកសិកម្មលើដីស្រែផ្ទាល់ខ្លួន ឬធ្វើការងារកសិកម្មដែលពុំទទួលបាននូវប្រាក់កម្រៃ។ នៅកម្ពុជាមានគ្រួសារកសិករចំនួន ២.៣លានគ្រួសារ ដែលក្នុងនោះ៨០% (១,៦១៨,៥៨៨ គ្រួសារ) មានបុរសជាមេគ្រួសារ និង២០% (៤១២,៥១០ គ្រួសារ) មានស្ត្រីជាមេគ្រួសារ[៥]។

ស្ត្រីជាកសិករនៅកម្ពុជាដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រែក្លាយផលិតផលកសិកម្ម ឲ្យទៅជាសន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងគ្រួសាររបស់ពួកគាត់។ ស្ត្រីជាអ្នកទទួលបន្ទុកក្នុងផលិតកម្មស្បៀង ជ្រើសរើស និងរៀបចំអាហារ និងមានភារៈកិច្ចថៃទាំ និងចិញ្ចឹមកូន ហើយក៏ទទួលខុសត្រូវយ៉ាងសំខាន់សម្រាប់សន្តិសុខស្បៀងនៅក្នុងគ្រួសារ។ ស្ត្រីកាន់តែមានការពាក់ព័ន្ធទៅនឹងផលិតកម្មកសិកម្មដែលផ្តោតលើពាណិជ្ជកម្ម ជាពិសេសក្នុងខ្សែសង្វាក់ផលិតកម្មកសិកម្ម។

---

២. ឯកសារយេនឌ័រជាតិស្តីពីគ្រួសារកសិកម្ម រៀបរៀងដោយអង្គការស្បៀងអាហារ និងកសិកម្ម នៃអង្គការសហប្រជាជាតិ វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ កម្ពុជា ឆ្នាំ ២០១០

៣. ជំរឿនកសិកម្មនៅកម្ពុជា របាយការណ៍បឋម របស់វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការដោយសហការណ៍នឹងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ ២០១៣

៤. កម្ពុជា: យេនឌ័រក្នុងការវាយតម្លៃកសិកម្ម រៀបរៀងដោយធនាគារពិភពលោក ឆ្នាំ ២០១៤ (សេចក្តីព្រាងបឋម)

៥. ឯកសារយេនឌ័រជាតិស្តីពីគ្រួសារកសិកម្ម រៀបរៀងដោយអង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ កម្ពុជា ឆ្នាំ ២០១០

ស្ត្រីនៅកម្ពុជាមានតួនាទីសំខាន់នៅក្នុងទីផ្សារលក់ដុំ និងលក់រាយនៃផលិតផលកសិកម្ម។ ស្ត្រីជាអ្នកប្រមូលទិញ ជាឈ្មួញ ឬ ជាអ្នកលក់យ៉ាងសំខាន់ ដែលធ្វើការងារក្នុងទីផ្សារនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់តំបន់។ លើសពីនេះទៅទៀត ស្ត្រីជាដៃគូយ៉ាងសកម្មក្នុងការផ្គត់ផ្គង់ធនធាន ឬធាតុចូលសម្រាប់កសិ-ពាណិជ្ជកម្ម ដោយធ្វើការងារផ្ទាល់ជាមួយអតិថិជន និងដោយផ្តល់នូវព័ត៌មាន និងចំណេះដឹងពីការប្រើប្រាស់ធនធាន ឬធាតុចូល ដូចជា ជី និងថ្នាំសម្លាប់សត្វល្អិត។

## ៣.១.និន្នាការបច្ចុប្បន្ន និងហានិភ័យ

ការប្រែប្រួលអាកាសធាតុ យន្តូបនីយកម្ម និងការធ្វើចំណាកស្រុកកំពុងតែមានឥទ្ធិពលលើវិស័យកសិកម្មនៅកម្ពុជាយ៉ាងពិតប្រាកដ ជាពិសេសលើកម្លាំងពលកម្ម ការចូលរួម តួនាទី និងទំនាក់ទំនងយេនឌ័រ។ ការប្រែប្រួល និងនិន្នាការទាំងអស់នេះបានបង្ហាញឲ្យឃើញពីឱកាស ប៉ុន្តែក៏បានបង្កនូវភាពមិនច្បាស់លាស់គួរឲ្យកត់សម្គាល់ក្នុងការដោះស្រាយបញ្ហាយេនឌ័រនៅក្នុងវិស័យនេះ។

ការគំរាមកំហែងដោយការប្រែប្រួលអាកាសធាតុ ដែលលេចឡើងយ៉ាងច្បាស់ ដោយសារគ្រោះរាំងស្ងួតរយៈពេលវែង ព្យុះ និងទឹកជំនន់ ត្រូវបានគេទទួលស្គាល់ជាបញ្ហាប្រឈមដ៏ចម្បងមួយ ដល់ការអភិវឌ្ឍជាសាកល។ មានភស្តុតាងយ៉ាងច្បាស់ដែលបានបង្ហាញថា ការប្រែប្រួលអាកាសធាតុមានឥទ្ធិពលមិនដូចគ្នាមកលើបុរស និងស្ត្រី។ បុរស និងស្ត្រីអាចរួមចំណែកក្នុងការកាត់បន្ថយ និងបន្សុំាទៅនឹងបម្រែបម្រួលអាកាសធាតុតាមរបៀបផ្សេងៗគ្នា ប៉ុន្តែអាចបំពេញឲ្យគ្នាទៅវិញទៅមកបាន ។

ក្នុងប្រទេសកម្ពុជានៅខណៈដែលកសិករភាគច្រើនពឹងផ្អែកលើទឹកភ្លៀងសម្រាប់ធ្វើកសិកម្ម និងធនធានធម្មជាតិជាប្រភពចម្បងនៃចំណូលក្នុងគ្រួសារ ការប្រែប្រួលអាកាសធាតុបានគំរាមកំហែងដោយផ្ទាល់លើជីវភាពរបស់ប្រជាជន ទាំងក្នុងរយៈពេលខ្លី និងរយៈពេលវែង[៦] ។ ភាពងាយរងគ្រោះរបស់ស្ត្រីដោយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជាកាន់តែធ្ងន់ធ្ងរឡើងៗ ដោយសារកង្វះចំណេះដឹង និងលទ្ធភាពទទួលបានធនធាន។ ជាទូទៅស្ត្រីមិនមែនជាអ្នកដែលទទួលនូវសេវាផ្សព្វផ្សាយនោះទេ ពីព្រោះពួកគាត់ពុំសូវមានលទ្ធភាពទទួលបាននូវព័ត៌មានអំពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ និងប្រភពបច្ចេកទេសដែលពាក់ព័ន្ធនានា។ ស្ត្រីក៏ពុំអាចទទួលបាននូវសេវាកម្ម និងយន្តការហិរញ្ញវត្ថុដែលអាចផ្តល់ការគាំទ្រដល់គំនិតផ្តួចផ្តើមនៃការកាត់បន្ថយ និងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ។ ការយកចិត្តទុកដាក់លើការផ្តល់នូវព័ត៌មានអំពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ និងការអនុវត្តថ្មីៗ ក្នុងការគាំទ្រដល់ការកាត់បន្ថយនិងការបន្សុំាទៅនឹងបម្រែបម្រួលអាកាសធាតុ បានផ្តល់នូវឱកាសសម្រាប់សេវាកម្ម ដែលអាចបំពេញនូវតម្រូវការជាក់ស្តែង និងចំណាប់អារម្មណ៍ជាយុទ្ធសាស្ត្ររបស់ស្ត្រី។ នៅក្នុងបរិបទនេះ រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តផែនការសកម្មភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុ[៧](២០១៤-២០១៨) និងកំណត់ការកាត់បន្ថយបម្រែបម្រួលអាកាសធាតុ និងការអភិវឌ្ឍបៃតងជាយុទ្ធសាស្ត្រ ដែលផ្តោតសម្រាប់ការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី [៨]។

៦. ការវាយតម្លៃយេនឌ័រនៅកម្ពុជា សង្ខេបគោលការណ៍៣ ការផ្តល់សិទ្ធអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី របស់ក្រសួងកិច្ចការនារី ឆ្នាំ ២០១៤

៧. ផែនការសកម្មភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (២០១៤-២០១៨) ក្រសួងកិច្ចការនារី

៨. ការវាយតម្លៃយេនឌ័រនៅកម្ពុជា សង្ខេបគោលការណ៍ ១០ យេនឌ័រ និងការប្រែប្រួលអាកាសធាតុរបស់ក្រសួងកិច្ចការនារី ឆ្នាំ ២០១៤

យន្តូបនីយកម្ម និងការណែនាំនូវបច្ចេកវិទ្យាថ្មីៗ មានឥទ្ធិពលផ្សេងៗគ្នាទៅលើកសិករជាបុរស និងជាស្ត្រី។ យន្តូបនីយកម្មនេះអាចបង្កើនផលិតកម្មនិងកាត់បន្ថយបន្ទុកការងារស្ត្រីជាកសិករ និងជួយសម្រួលដល់ការងារធ្ងន់ៗបានមួយចំនួនទៀតផង[៩] ។ នៅប្រទេសកម្ពុជាមានកិច្ចខិតខំប្រឹងប្រែងតិចតួចណាស់ដែលត្រូវបានធ្វើឡើងក្នុងការបណ្តុះបណ្តាលដល់ស្ត្រីលើការប្រើប្រាស់គ្រឿងម៉ាស៊ីន និងបច្ចេកវិទ្យាថ្មីៗ។ សកម្មភាពប្រមូលផល និងក្រោយប្រមូលផលជារឿយៗ ដែលធ្វើឡើងដោយស្ត្រីត្រូវបានជំនួសមកវិញដោយការប្រើប្រាស់ម៉ាស៊ីនដែលដំណើរការដោយបុរស[១០]។ យន្តូបនីយកម្មអាចមានឥទ្ធិពលមិនល្អដល់អ្នកគ្មានដីធ្លី និងស្ត្រីជាកសិករ ហើយភាពលំអៀងផ្នែកសង្គម ដែលផ្សារភ្ជាប់ការប្រើប្រាស់ម៉ាស៊ីនជាមួយបុរស បានបន្ថយកម្រិតប្រើប្រាស់បច្ចេកវិទ្យាចំពោះស្ត្រី។

ចំណាកស្រុកមានឥទ្ធិពលយ៉ាងខ្លាំងទៅលើតួនាទីយេនឌ័រ និងការបែងចែកកម្លាំងពលកម្មជនបទនៅកម្ពុជា ហើយចំណាកស្រុកអាចមានឥទ្ធិពលទៅលើកម្រិត នៃការចូលរួមរបស់ស្ត្រីនៅក្នុងខ្សែសង្វាក់ផលិតកម្មកសិកម្ម។ កត្តាគន្លឹះដែលធ្វើឲ្យមានការប្រែប្រួលនេះ បណ្តាលមកពីមានការកើនឡើង នៃការធ្វើចំណាកស្រុករបស់ស្ត្រី និងបុរសវ័យក្មេងទៅធ្វើការនៅរោងចក្រកាត់ដេរ។ ភាពក្រីក្រ ប្រាក់ចំណូលមិនគ្រប់គ្រាន់ពីកសិកម្ម និងការជំពាក់បំណុល គឺជាមូលហេតុចម្បង សម្រាប់គ្រួសារនៅជនបទក្នុងការធ្វើសេចក្តីសម្រេចចិត្តចំណាកស្រុក ឬបញ្ជូនសមាជិកគ្រួសារឲ្យទៅរកការងារធ្វើនៅឆ្ងាយពីផ្ទះ។ ជារឿយៗគ្រួសារនៅជនបទនៅសល់តែមនុស្សចាស់ និងកុមារ ឬនៅពេលបុរសធ្វើចំណាកស្រុក គឺនៅសល់តែស្ត្រី និងកុមារ។

នៅក្នុងតំបន់ដែលមានបុរសធ្វើចំណាកស្រុកទៅធ្វើការនៅប្រទេសថៃ ត្រូវបានកត់សម្គាល់ជាសំខាន់ថា ស្ត្រីបានក្លាយជាអ្នកគ្រប់គ្រងកសិដ្ឋានកាន់តែច្រើនឡើងជាមួយនឹងការផ្តល់ឱកាសថ្មីផងដែរ ដូចជាការគ្រប់គ្រងលើធនធាន និងធ្វើឲ្យស្ថានភាពសេដ្ឋកិច្ចសង្គមគ្រួសារ កាន់តែប្រសើរឡើង។ ចំណាកស្រុកអាចបង្កើននូវតម្រូវការ និងឱកាសដើម្បីបង្កើតសេវាកម្ម ដូចជាទីផ្សារប្រាក់សន្សំ សម្រាប់ប្រាក់ដែលសមាជិកផ្ញើមក សេវាថែទាំកុមារក្នុងភូមិ និងការអភិវឌ្ឍកសិ-ពាណិជ្ជកម្មខ្នាតតូច សម្រាប់ស្ត្រីវ័យក្មេងនៅជនបទ។

ទស្សនវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់វិស័យកសិកម្ម គឺធ្វើការផ្លាស់ប្តូរវិស័យនេះឲ្យក្លាយទៅជាកសិកម្មបែបពាណិជ្ជកម្ម តាមរយៈការបង្កើនផលិតភាព និងពិពិធកម្មកសិកម្ម ក៏ដូចជាលទ្ធភាពទទួលបានទីផ្សារ។ ការយល់ដឹងអំពីដំណើរការនៃការប្រែប្រួលយ៉ាងខ្លាំង និងនិន្នាការដែលកើតឡើង និងឥទ្ធិពលផ្សេងៗគ្នារបស់វាទៅលើស្ត្រី និងបុរស ចាំបាច់ណាស់ក្នុងការធ្វើឲ្យវិស័យនេះកាន់តែប្រសើរឡើង ដែលមានកំណើនឆាប់រហ័ស និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ នៅក្នុងបរិបទនេះ ទស្សនៈយេនឌ័រមានសារៈសំខាន់ណាស់ក្នុងការស្វែងយល់ពីឥទ្ធិពលនៃការវិនិយោគដីធ្លីខ្នាតធំ និងពីការផ្លាស់ប្តូរទៅជាកសិ-ពាណិជ្ជកម្មខ្នាតធំ។ ការផ្លាស់ប្តូរទាំងនេះជារឿយៗ បានបណ្តាលឲ្យមានការប្រែប្រួលនៅក្នុងតួនាទីរបស់គ្រួសារ សកម្មភាពរកប្រាក់ចំណូល និងសិទ្ធិកាន់កាប់ដីធ្លី។ រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថាបុរស និងស្ត្រីបានចូលរួមចំណែកក្នុងការសម្រេចបាននូវលទ្ធផលនៃការអភិវឌ្ឍ ហើយសមភាពយេនឌ័រគឺជាគន្លឹះសំខាន់សម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម។

---

៩. http://www.oxfamamerica.org/expore/stories/mechaical-advantage/-ឧបករណ៍គំចាត់ស្មៅ (នាគស្រែ) បង្កើនទិន្នផលបន្ថែម ១តោន/ហិចតា និងសន្សំពេល និងកំលាំង ៨0% ។ Oxfam គាំទ្រ RACHANA ក្នុងការធ្វើតេស្ត និងរចនាប្លង់

១០. កម្ពុជា: យេនឌ័រក្នុងការវាយតម្លៃកសិកម្ម រៀបរៀងដោយធនាគារពិភពលោក ឆ្នាំ ២០១៤ (សេចក្តីព្រាងបឋម)

## ៣.២. ការវាយតម្លៃយេនឌ័រក្នុងវិស័យ និងអនុ-វិស័យកសិកម្ម

### ស្ត្រី និងអក្ខរភាព

គម្លាតយេនឌ័រនៅក្នុងអក្ខរកម្មនៅកម្ពុជាបានធ្លាក់ចុះ។ ៧២% នៃមេគ្រួសារដែលប្រកបរបរកសិកម្មចេះអាន និងចេះសរសេរលិខិតសាមញ្ញបាន។ យ៉ាងណាក៏ដោយប្រមាណជា ២៩% នៃស្ត្រីកម្ពុជាដែលមានអាយុចន្លោះពី ១៥ឆ្នាំ និងលើសពីនេះមិនចេះអក្សរបើប្រៀបធៀបទៅនឹងបុរសដែលមានត្រឹមតែ ១៥% ប៉ុណ្ណោះ[១១]។ បើយោងទៅតាមទិន្នន័យជំរឿនទូទាំងប្រទេសឆ្នាំ២០១១ បានឲ្យដឹងថាស្ត្រីប្រមាណ ៦៩% អាចចេះអាន និងចេះសរសេរបើធៀបទៅនឹងបុរសដែលចេះអក្សរគឺ ៨៥%[១២] ។ គម្លាតយេនឌ័រ គឺកាន់តែខ្ពស់រវាងបុរស និងស្ត្រីដែលជាមេគ្រួសារ។ អក្ខរកម្មក្នុងចំណោមស្ត្រីជាមេគ្រួសារកសិករគឺមានចំនួនប្រមាណ៤២% បើធៀបនឹងកសិករបុរសជាមេគ្រួសារមានរហូតទៅដល់ ៨០%[១៣]។

### តំណាងស្ត្រីនៅក្នុងរដ្ឋបាលកសិកម្ម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានមន្ត្រីរាជការសរុបប្រមាណ ៦,៦២៩ នាក់ ក្នុងនោះស្ត្រីមានប្រមាណ ២០%។ ស្ត្រីចំនួន ២០.៤% បម្រើការងារជាមន្ត្រីក្នុងផ្នែកកសិកម្ម ៧.៧% ក្នុងផ្នែករដ្ឋបាលព្រៃឈើ ៣០% ក្នុងផ្នែកផលិតកម្មសត្វ និង ១៤.៦% បម្រើការងារក្នុងផ្នែកជលផល។ មានស្ត្រីចំនួន ១២% បម្រើការងារជាអ្នកផ្សព្វផ្សាយកសិកម្ម។

តំណាងស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេចចិត្តនៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានចំនួនតិចតួចនៅឡើយក្នុងគ្រប់អនុវិស័យ។ ទោះបីជាយ៉ាងណាក៏ដោយនៅឆ្នាំ២០១៣ សម្រាប់អាណត្តិទី៥របស់រាជរដ្ឋាភិបាលកម្ពុជា(២០១៣-២០១៨) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានតែងតាំងស្ត្រី២រូប ក្នុងតួនាទីជាអ្នកដឹកនាំជាន់ខ្ពស់ ហើយក្នុងនោះស្ត្រី១រូប ជារដ្ឋលេខាធិការ និងស្ត្រី១រូប ជាអនុរដ្ឋលេខាធិការ។ ស្ត្រីចំនួន ៣៥% ជាមន្ត្រីដែលបានជ្រើសរើសថ្មីសម្រាប់ឆ្នាំ២០១៤។

នៅសាកលវិទ្យាល័យភូមិន្ទកសិកម្មមាននិស្សិតស្រីចំនួន២៣% នៃនិស្សិតសរុប។ ក្នុងនោះនិស្សិតស្រីថ្នាក់បរិញ្ញាបត្រមានចំនួន២២%។ និស្សិតចំនួន២២ រូប ក្នុងចំណោមនិស្សិតសាលាក្រោយឧត្តម១៧៣ រូប គឺជាស្ត្រីនិងនិស្សិតចំនួន ១៩រូប ក្នុងចំណោមនិស្សិតចំនួន ៨២រូប ដែលបានចុះឈ្មោះថ្នាក់បរិញ្ញាបត្ររង គឺជាស្ត្រី។ មានសាលាជាតិកសិកម្ម ចំនួន២៖ សាលាជាតិកសិកម្មព្រែកលៀប មាននិស្សិតចំនួន ១៥៦២រូប ក្នុងនោះនិស្សិតស្រីចំនួន ៥០២រូប និងសាលាជាតិកសិកម្មកំពង់ចាម ដែលមាននិស្សិតចំនួន ១៥៥៩រូប ក្នុងនោះនិស្សិតស្រីចំនួន ៦០៨រូប។

---

១១. កម្ពុជា: យេនឌ័រក្នុងការវាយតម្លៃកសិកម្ម រៀបរៀងដោយធនាគារពិភពលោក ឆ្នាំ ២០១៤ (សេចក្តីព្រាងបឋម)

១២. ជំនួញភាវូនីយកម្មដំណាំស្រូវដែលធន់នឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា: ការវាយតម្លៃសេដ្ឋកិច្ចសង្គម និងការវិភាគយេនឌ័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ឆ្នាំ ២០១២

១៣. ឯកសារយេនឌ័រជាតិស្តីពីគ្រួសារកសិកម្ម អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ កម្ពុជាឆ្នាំ ២០១០

ស្ត្រីស្មើនឹង ៣៨% នៃសមាជិកសហគមន៍ជលផលចំនួន៥១៦ សហគមន៍ និង ៤០% នៃសមាជិកសហគមន៍ព្រៃឈើចំនួន៤៥៧សហគមន៍។ នៅក្នុងសហគមន៍ជលផលចំនួន៣កន្លែងមានស្ត្រីជាប្រធានសហគមន៍។ ក្នុងសហគមន៍ព្រៃឈើស្ត្រីចំនួន ៥% មានតួនាទីជាប្រធានសហគមន៍ និង៣០% មានតួនាទីជាអនុប្រធានសហគមន៍។ នៅក្នុងសហគមន៍អភិវឌ្ឍន៍កសិកម្មមានចំនួន៥៥៦ សហគមន៍ ក្នុងនោះស្ត្រីស្មើនឹង ៦១,៦ % ជាសមាជិកសហគមន៍ និង១១២នាក់ ជាអ្នកដឹកនាំសហគមន៍។ ១០% នៃកសិដ្ឋានចិញ្ចឹមបក្សី និងផលិតចំណីសត្វចំនួន២៦៣ កសិដ្ឋានត្រូវបានគ្រប់គ្រងដោយស្ត្រី។

## ស្ត្រី និងលទ្ធភាពទទួលបានសេវាផ្សព្វផ្សាយកសិកម្ម

សេវាផ្សព្វផ្សាយកសិកម្មសំដៅទៅលើវិសាលភាពនៃពត៌មាន ដំបូន្មាន គំនិតផ្តួចផ្តើមស្រាវជ្រាវ និងអភិវឌ្ឍន៍ ការបណ្តុះបណ្តាល និងចំណេះដឹងដែលទាក់ទងនឹងកសិកម្ម ជលផល ផលិតកម្មសត្វ ការកែច្នៃ និងទីផ្សារ។ សេវាផ្សព្វផ្សាយកសិកម្មកើតឡើងនៅក្នុងបរិបទនៃសង្គមវប្បធម៌ជាក់លាក់ ហើយលទ្ធភាពទទួលបាន និងប្រសិទ្ធភាពនៃសេវាកម្មទាំងនេះ បានទទួលឥទ្ធិពលយ៉ាងខ្លាំងពីលក្ខខណ្ឌសង្គម និងសង្គមនយោបាយ ដែលមានទំនាក់ទំនងទៅនឹងយេនឌ័រ។ គម្លាតយេនឌ័រក្នុងការទទួលបាននូវសេវាកម្មគាំទ្រ និងផ្សព្វផ្សាយកសិកម្មនៅកម្ពុជា គឺជាបញ្ហាប្រឈមដែលកើតមានឡើងតាំងពីយូរមកហើយ។ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការបង្កើនសេវាផ្សព្វផ្សាយសម្រាប់បុរស និងស្ត្រីយ៉ាងណាក៏ដោយ ក៏សេវាកម្មផ្សព្វផ្សាយនៅកម្ពុជានៅតែមានបុរសជាភ្នាក់ងារផ្សព្វផ្សាយច្រើនលើសលប់ ដែលទំនងជាផ្តោតទៅលើការចែកចាយសេវាកម្មទៅដល់កសិករជាបុរសដូចគ្នា[១៤]។ ក្នុងស្ថានភាពនេះ ជាទូទៅបុរសត្រូវបានគេចាត់ទុកជាមេគ្រួសារ ហើយជាអ្នកដែលទទួលបានព័ត៌មានថ្មីៗដោយស្វ័យប្រវត្តិ។

កត្តាប្រឈមដែលមានឥទ្ធិពលលើលទ្ធភាពរបស់ស្ត្រីជនបទនៅកម្ពុជា ក្នុងការទទួលបាននូវសេវាផ្សព្វផ្សាយកសិកម្មគ្រប់គ្រាន់មានដូចជា៖ ទីតាំងផ្តល់សេវាផ្សព្វផ្សាយនៅឆ្ងាយ ភាពមានកម្រិតនៃការចេះអក្សរ កង្វះពេលវេលា កង្វះសេវាថែទាំកុមារ បន្ទុកការងារផ្ទះច្រើន ការមិនអាចធ្វើដំណើរទៅឆ្ងាយ និងលក្ខណៈសង្គមវប្បធម៌ជាច្រើនទៀត។

## ស្ត្រី និងការទទួលបាននូវឧបករណ៍ និងបច្ចេកវិទ្យាកសិកម្ម

គ្រឿងយន្តកសិកម្ម នៅតែស្ថិតនៅឆ្ងាយពីដៃស្ត្រីជាកសិករនៅកម្ពុជា។ បច្ចុប្បន្ននេះ ការសិក្សាពីវិស័យកសិកម្មបានបង្ហាញថា ការប្រើប្រាស់គ្រឿងយន្តបានជួយកាត់បន្ថយបន្ទុកការងាររបស់កសិករជាស្ត្រី និងជួយបង្កើនផលិតភាពរបស់ពួកគាត់។ ស្ថិតិជាតិចុងក្រោយបំផុតដែលអាចរកបាន បានបង្ហាញថាមានភាពខុសគ្នាគួរឲ្យកត់សម្គាល់រវាងបុរស និងស្ត្រីជាកសិករក្នុងការទទួលបានឧបករណ៍និងសម្ភារកសិកម្មនៅកម្ពុជា។ គ្រួសារកសិករដែលមានបុរសជាមេគ្រួសារ មានលទ្ធភាពប្រើប្រាស់គ្រឿងយន្តកសិកម្ម ច្រើនជាងគ្រួសារដែលមានស្ត្រី

១៤. កម្ពុជា: យេនឌ័រក្នុងការវាយតម្លៃកសិកម្ម រៀបរៀងដោយធនាគារពិភពលោក ឆ្នាំ ២០១៤ (សេចក្តីព្រាងបឋម)

ជាមេគ្រួសារចំនួន៧ដង និងមានលទ្ធភាពប្រើប្រាស់ម៉ាស៊ីនបូមទឹកច្រើនជាងស្ត្រីជាមេគ្រួសារ ចំនួន២ដង[១៥]។ ចំពោះការប្រើប្រាស់នង្គ័លវិញ សមាមាត្រនៃគ្រួសារដែលមានបុរសជាមេគ្រួសារគឺខ្ពស់ជាងគ្រួសារដែលមានស្ត្រីជាមេគ្រួសារចំនួន១៧%។ ស្ត្រីក៏ពុំសូវមានលទ្ធភាពក្នុងការប្រើប្រាស់ម៉ាស៊ីនបោកស្រូវ និងម៉ាស៊ីនកិនស្រូវខ្នាតតូចសម្រាប់បម្រើដល់គោលបំណងកែច្នៃផលិតផលកសិកម្មនោះដែរ ។ អត្រាតិចតួចណាស់នៃស្ត្រីជាមេគ្រួសារដែលមានម៉ាស៊ីនបោកស្រូវសម្រាប់ប្រើប្រាស់ (០.២%) និងមានម៉ាស៊ីនកិនស្រូវប្រើប្រាស់ (១%)។ ផ្ទុយទៅវិញ អត្រានៃកសិករបុរសជាមេគ្រួសារដែលមានលទ្ធភាពទទួលបានម៉ាស៊ីនបោកស្រូវ (១.៣%) និងម៉ាស៊ីនកិនស្រូវ (៣.៧ %) គឺមានកម្រិតខ្ពស់ជាងស្ត្រី[១៦] ។

### លទ្ធភាពទទួលបានសេវាកម្មហិរញ្ញវត្ថុរបស់ស្ត្រី

ស្ត្រីអាចក្លាយជាអ្នកមានអំណាចផ្នែកសេដ្ឋកិច្ច ដោយវិធីសាស្ត្រជាច្រើនបែប តាមរយៈការទទួលបាននូវសេវាកម្មហិរញ្ញវត្ថុ។ តាមរយៈប្រាក់សន្សំ ឥណទាន ស្ថាប័នធានារ៉ាប់រង និងសកម្មភាពផ្តល់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ នោះស្ត្រីអាចធ្វើឲ្យប្រសើរឡើងនូវសកម្មភាពសេដ្ឋកិច្ចផ្ទាល់ខ្លួន បង្កើត និងការពារទ្រព្យសម្បត្តិឈានចូលទៅក្នុងទីផ្សារ និងធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចរបស់ខ្លួន។ ទោះបីជាមានសក្តានុពលយ៉ាងច្រើននៃសេវាកម្មហិរញ្ញវត្ថុជនបទសម្រាប់កសិករជាស្ត្រីនៅកម្ពុជាក៏ដោយ ក៏នៅតែជាផ្លូវមួយដ៏វែងឆ្ងាយសម្រាប់ស្ត្រីក្នុងការទទួលបានលទ្ធភាពក្នុងការប្រើប្រាស់ដោយស្មើភាព ឬទទួលផលប្រយោជន៍ពីសេវាកម្មទាំងនេះ ឲ្យបានពេញលេញ។ ការសម្រេចបាននូវគោលដៅទាំង២នេះមិនត្រឹមតែអាស្រ័យលើការពង្រីកសេវាកម្មហិរញ្ញវត្ថុប៉ុណ្ណោះទេ ប៉ុន្តែក៏អាស្រ័យផងដែរទៅលើប្រភេទជាក់លាក់នៃសេវាកម្មហិរញ្ញវត្ថុ ដែលបានចែកចាយក្នុងបរិបទផ្សេងៗគ្នាសម្រាប់ស្ត្រីជាកសិករដែលមកពីប្រភពខុសៗគ្នា និងទៅតាមប្រភេទស្ថាប័ន ឬកម្មវិធីផ្សេងៗគ្នាផងដែរ។

ជាញឹកញាប់ស្ត្រីជាកសិករទំនងជាខ្ចីធនធាន ឬធាតុចូល (គ្រាប់ពូជ នង្គ័ល និងម៉ាស៊ីនបូមទឹក) ដែលត្រូវបានគណនាជាតម្លៃទឹកប្រាក់ ហើយត្រូវបានរាប់បញ្ចូលជាបំណុលពីអ្នកផ្គត់ផ្គង់។ ពួកគាត់ត្រូវបង់ថ្លៃជំពាក់ទាំងនោះវិញនៅពេលដែលប្រមូលផល ឬភ្លាមៗបន្ទាប់ពីស្ត្រីលក់ផលដំណាំបាន។ យ៉ាងណាមិញ ទិន្នផលទាបឬការខូចខាតផលដំណាំដោយសារតែគ្រោះធម្មជាតិ បានរុញច្រានស្ត្រី និងជាពិសេសមេគ្រួសារជាស្ត្រីឲ្យធ្លាក់ចូលទៅក្នុងស្ថានភាពលំបាកដោយសារតែការសងបំណុល និងកង្វះស្បៀងអាហារ។ បញ្ហាបំណុលដែលទាក់ទងនឹងអ្នកផ្គត់ផ្គង់ធនធានផលិតកម្ម អាចមានឥទ្ធិពលទៅលើលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានតម្លៃលក់ ឬទីផ្សារ ប៉ុន្តែតម្លៃលក់ឬទីផ្សារប្រសើរជាងមុន តាមរយៈការធ្វើសកម្មភាពសហគមន៍រួមគ្នា និងការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យា។

១៥. ឯកសារយេនឌ័រជាតិស្តីពីគ្រួសារកសិកម្ម អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ កម្ពុជា ឆ្នាំ ២០១០

១៦. ឯកសារយេនឌ័រជាតិស្តីពីគ្រួសារកសិកម្ម អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ កម្ពុជាឆ្នាំ ២០១០

ស្ថិតិជាតិបានបង្ហាញថា៣៧% នៃគ្រួសារកសិករទាំងអស់នៅកម្ពុជា បានប្រើប្រាស់ឥណទាន។ ការបែងចែកទៅតាមភេទ គឺ ៣៣.៤% ជាគ្រួសារកសិករដែលមានស្ត្រីជាមេគ្រួសារ និង ៣៨.១% ជាគ្រួសារកសិករដែលមានបុរសជាមេគ្រួសារ[១៧]។ កសិករដែលមានស្ត្រីជាមេគ្រួសារ (៨.៩%) ទទួលបានប្រាក់កម្ចីពីឈ្មួញកណ្តាល (អ្នកចងការប្រាក់) ច្រើនជាងកសិករដែលមានបុរសជាមេគ្រួសារ (៧.៧%)។ ទន្ទឹមគ្នានេះដែរ គ្រួសារកសិករមានបុរសជាមេគ្រួសារ (៩.១%) ដែលទទួលបានប្រាក់កម្ចីពីធនាគារមានចំនួនច្រើនជាងស្ត្រីជិត២ដងបើប្រៀបធៀបជាមួយនឹងកសិករដែលមានស្ត្រីជាមេគ្រួសារ ដែលប្រើប្រាស់សេវាប្រាក់កម្ចីពីធនាគារនេះត្រឹមតែ៥.៣% ប៉ុណ្ណោះ[១៨]។ ស្ថាប័នមីក្រូហិរញ្ញវត្ថុ និងធនាគារបានផ្តល់ជូនប្រាក់កម្ចីនូវអត្រាការប្រាក់ទាបជាង ឈ្មួញកណ្តាល (អ្នកចងការប្រាក់) ដែលយកការប្រាក់ចន្លោះពី៥% ទៅ ៧% ក្នុងមួយខែ ប៉ុន្តែស្ថាប័នទាំងនេះ បានតម្រូវឲ្យដាក់របស់បញ្ចាំដើម្បីធានានូវសុវត្ថិភាពនៃប្រាក់កម្ចី ហើយកាលបរិច្ឆេទសងប្រាក់ពុំអាចផ្លាស់ប្តូរ បានឡើយ[១៩]។

## លទ្ធភាពទទួលបានដីធ្លីរបស់ស្ត្រី

ការទទួលស្គាល់ និងការចុះបញ្ជីក្បាលដីជាផ្លូវការ បានក្លាយទៅជាផ្នែកមួយនៃដំណើរការកំណែទម្រង់សេដ្ឋកិច្ចនៅកម្ពុជាក្នុងរយៈពេលមួយទសវត្សកន្លងទៅនេះ។ អ្នករៀបចំគោលនយោបាយបានអះអាងថាការធានានូវប័ណ្ណកម្មសិទ្ធិឯកជន នឹងជួយបង្កើននូវសុវត្ថិភាពនៃកម្មសិទ្ធិដីធ្លី នៅខណៈពេលជួយលើកកម្ពស់ទីផ្សារដីធ្លីឲ្យមានប្រសិទ្ធភាព។ នៅក្នុងបរិបទនេះ រាជរដ្ឋាភិបាលកម្ពុជាបានផ្តួចផ្តើមកំណែទម្រង់ច្បាប់ជាច្រើនដោយរួមមានការអនុម័តច្បាប់ដីធ្លីឆ្នាំ២០០១ ដែលត្រូវបានដាក់ឲ្យប្រតិបត្តិតាមរយៈការអនុវត្តបទបញ្ជា និងការណែនាំផ្សេងៗ។ បន្ទាប់ពីការអនុម័តច្បាប់ដីធ្លីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ បានរៀបចំយុទ្ធនាការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធ។ គោលនយោបាយរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងដីធ្លី មានគោលបំណងការពារសិទ្ធិស្ត្រី ក្នុងដំណើរការកំណែទម្រង់ដីធ្លីនេះបន្ទាប់ពីមានក្របខ័ណ្ឌការងារជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីគោលនយោបាយដីធ្លី។ ក្របខ័ណ្ឌការងារនេះបានទទួលស្គាល់ថា "ដើម្បីឲ្យគោលនយោបាយដីធ្លីបំពេញទៅតាមតម្រូវការរបស់ប្រជាជនកម្ពុជាទាំងអស់ គោលនយោបាយនេះត្រូវតែឆ្លើយតបទៅនឹងតម្រូវការរបស់ស្ត្រី"។ គោលការណ៍ចំបងមួយ នៃការឆ្លើយតបនេះ គឺថាការចុះបញ្ជីក្បាលដីនឹងនៅបន្តមានក្នុងទម្រង់ជាម្ចាស់កម្មសិទ្ធិរួមគ្នាដែលមានឈ្មោះប្តី និងប្រពន្ធ។

កត្តាប្រឈមនៃយេនឌ័រចំពោះការចុះបញ្ជីដីធ្លីរួមមាន បញ្ហាក្នុងការទទួលបាននូវព័ត៌មានស្តីពីដំណើរការចុះបញ្ជីក្បាលដី ការលំបាករបស់ស្ត្រីជាមេគ្រួសារក្នុងការទទួលបានលិខិតស្នាមដែលបញ្ជាក់ពីស្ថានភាពនៅលីវរបស់ខ្លួនដែលបង្អាក់លទ្ធភាពក្នុងការចុះបញ្ជីដីធ្លី និងអតុល្យភាពយេនឌ័រក្នុងការគ្រប់គ្រងនិងធ្វើការសម្រេចចិត្ត[២០]។

១៧. ឯកសារយេនឌ័រជាតិស្តីពីគ្រួសារកសិកម្ម អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ កម្ពុជាឆ្នាំ ២០១០

១៨. ឯកសារយេនឌ័រជាតិស្តីពីគ្រួសារកសិកម្ម អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ កម្ពុជាឆ្នាំ ២០១០

១៩. កម្ពុជា: យេនឌ័រក្នុងការវាយតម្លៃកសិកម្ម រៀបរៀងដោយធនាគារពិភពលោក ឆ្នាំ ២០១៤ (សេចក្តីព្រាងបឋម)

២០. ទស្សនៈវិស័យរបស់ស្ត្រី: ករណីសិក្សានៃការបញ្ជីដីធ្លីជាប្រព័ន្ធ រៀបរៀងដោយ Hienrich Boll Foundation Mehrak Mehrvar ឆាយ គីមស័រ និង មី សម្បត្តិ ឆ្នាំ ២០០៨

ជំរឿនកសិកម្មឆ្នាំ២០១៣ បានរកឃើញថា៨៥% នៃគ្រួសារកសិករទាំងអស់នៅកម្ពុជាមានលទ្ធភាពទទួលបានដីកសិកម្ម ហើយដីស្រែជាមធ្យមក្នុងមួយគ្រួសារមានប្រមាណជា ១.៨ហិកតា។ បុរសមានចំនួន ១.៨លាននាក់ ឬស្មើទៅនឹង៧៣% នៃគ្រួសារកសិករដែលមានដីស្រែ និងស្ត្រីដែលមានដីធ្លីកាន់កាប់មានចំនួនតែ០.៥ លាននាក់ ឬស្មើនឹង២៧% (ក្នុងសមាមាត្របុរសចំនួន ២៦៨ នាក់ លើស្ត្រីចំនួន១០០ នាក់)[២១]។

ផលធៀបនៃកសិករបុរសជាមេគ្រួសារ ដែលមានលទ្ធភាពទទួលបានដីកសិកម្ម ខ្ពស់ជាងកសិករស្ត្រីជាមេគ្រួសារប្រមាណជា ៣%។ ភាពខុសគ្នាដ៏ទៃទៀតនៃលទ្ធភាពទទួលបានដីធ្លី រវាងបុរសជាមេគ្រួសារ និងស្ត្រីជាមេគ្រួសារនៅកម្ពុជា គឺជាចំនួនក្បាលដីដែលពួកគាត់មាន។ ស្ថិតិជាតិបង្ហាញឲ្យឃើញថា ៤៩% នៃស្ត្រីជាមេគ្រួសារមានក្បាលដីតែមួយកន្លែងខណៈដែល ៦១%នៃបុរសជាមេគ្រួសារមានក្បាលដីច្រើនជាងមួយកន្លែង[២២]។

## ការឈានចូលទីផ្សាររបស់ស្ត្រី

លទ្ធភាពទទួលបានទីផ្សារសម្រាប់លក់ ត្រូវបានពង្រីកចំពោះកសិករកម្ពុជា ទាំងបុរស និងស្ត្រី ក្នុងទសវត្សចុងក្រោយនេះ។ ការធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ការអនុវត្តវិធីសាស្ត្រ ខ្សែសង្វាក់ផលិតកម្មកសិកម្ម ដោយអ្នកពាក់ព័ន្ធផ្សេងៗគ្នារួមទាំងការប្រើប្រាស់ទូរស័ព្ទដៃទាំងអស់នេះ បានជួយសម្រួលដល់លទ្ធភាពទទួលបានទីផ្សារ ការកំណត់ថ្លៃ និងការកាត់បន្ថយលើការចំណាយផ្នែកទីផ្សារ។ អភិក្រមខ្សែសង្វាក់ផលិតកម្មនេះ បានពង្រឹងបណ្ដាញជំនួញរវាងក្រុមអ្នកផលិត អ្នកផ្ដល់សេវាកម្ម និងភ្នាក់ងារដទៃទៀត ដូចជាអ្នកកែច្នៃ និងអ្នកនាំចេញ ជាជាងការយកចិត្តទុកដាក់តែលើការអន្តរាគមន៍នៅនឹងកសិដ្ឋាន។ លក្ខណៈដែលគួរឲ្យកត់សម្គាល់នៃខ្សែសង្វាក់ផលិតកម្មកសិកម្មបែបទំនើប គឺជាកំណើននៃកសិកម្មបែបកិច្ចសន្យាដែលក្រុមហ៊ុនកែច្នៃផលិតផលកសិកម្មធំៗ ឬអ្នកជំនួញស្វះស្វែងធានានូវការផ្គត់ផ្គង់ផលិតផលកសិកម្មដែលមានគុណភាពឲ្យបានស្ថិតស្ថេរ។ គម្រោងផែនការបែបនេះអាចជួយកសិករខ្នាតតូច អ្នកចិញ្ចឹមសត្វ និងសហគមន៍នេសាទឲ្យមានលទ្ធភាពទទួលបាននូវធនធាន ឬធាតុចូលសម្រាប់កសិដ្ឋាន ដោយធានានូវតម្លៃសម្រាប់ផលិតផលកសិកម្ម និងបង្កើននូវប្រាក់ចំណូលខ្ពស់ជាងមុន។ លើសពីនេះទៅទៀត ក៏បានរួមចំណែកដល់ការដោះស្រាយរបាំងបច្ចេកទេស និងការចំណាយលើការធ្វើជំនួញដែលពាក់ព័ន្ធនឹងការបំពេញតម្រូវការទីផ្សារក្នុងស្រុក និងក្រៅស្រុកឲ្យកាន់តែច្រើនជាងមុន[២៣]។ ក្នុងឆ្នាំ២០១១ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យ ស្ដីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា ជាយុទ្ធសាស្ត្រសម្រាប់ខ្សែសង្វាក់ផ្គត់ផ្គង់ ដើម្បីកសាងបណ្ដាញទីផ្សារទៅវិញទៅមករវាងអ្នកលក់ និងអ្នកទិញដោយផ្អែកលើតុល្យភាព និងភាពយុត្តិធម៌ក្នុងការអភិវឌ្ឍវិស័យកសិកម្ម[២៤]។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាលកម្ពុជាបានអនុម័ត ច្បាប់ស្ដីពីសហគមន៍កសិកម្មនៅឆ្នាំ២០១៤។

---

២១. ជំរឿនកសិកម្មនៅកម្ពុជា របាយការណ៍បឋម របស់វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ដោយសហការណ៍ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ ២០១៣

២២. ឯកសារយេនឌ័រជាតិស្ដីពីគ្រួសារកសិកម្ម អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ កម្ពុជាឆ្នាំ ២០១០

២៣. ការសម្ភាសន៍ និងការពិភាក្សា ជាមួយនឹងបុគ្គលិករបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអ្នកពាក់ព័ន្ធ

២៤. ការសិក្សាអំពីឥទ្ធិពលនៃកសិកម្មស្រូវបែបកិច្ចសន្យាទៅលើចំណូលនៃកសិករខ្នាតតូច ក្នុងខេត្តកំពង់ស្ពឺ កម្ពុជា ដោយគង់ សុភ័ក្ត្រ សាកលវិទ្យាល័យភូមិន្ទកសិកម្ម ឆ្នាំ ២០១៤

ភាពខុសគ្នានៃយេនឌ័រ គឺកើតមាននៅកន្លែងការងារ ក្នុងខ្សែសង្វាក់តម្លៃទាំងមូល។ អភិក្រមយេនឌ័រចំពោះការវិភាគខ្សែសង្វាក់តម្លៃ បានធ្វើឲ្យមានការពិចារណាលើលទ្ធភាពទទួលបានសកម្មភាពផលិតរបស់បុរស និងស្ត្រីម្នាក់ៗ និងជាក្រុម ហើយក៏ពិចារណាលើឱកាសយេនឌ័រ ដែលខុសគ្នាតិចតួចសម្រាប់បង្កើនខ្សែសង្វាក់នេះ ការបែងចែកសកម្មភាពផ្អែកលើយេនឌ័រ ក្នុងខ្សែសង្វាក់តម្លៃដែលមានស្រាប់ និងទំនាក់ទំនងអំណាចយេនឌ័រដែលមានឥទ្ធិពល លើតម្លៃសេដ្ឋកិច្ចក្នុងចំណោមភ្នាក់ងារក្នុងខ្សែសង្វាក់ផលិតកម្ម[២៥]។

ស្ត្រីជាកសិករនៅកម្ពុជាបានផ្គត់ផ្គង់ទីផ្សារក្នុងស្រុកជាមួយនឹងផលិតផលកសិកម្ម ដែលមានតម្លៃខ្ពស់ និងមានលក្ខណៈជាប្រពៃណី ប៉ុន្តែបើធៀបជាមួយបុរស ស្ត្រីនៅតែប្រឈមនឹងគុណវិបត្តិមួយចំនួន ដូចជាមិនអាចចេញទៅឆ្ងាយ កម្រិតចំណេះដឹងនៅទាប ពុំសូវទទួលបាននូវការបណ្តុះបណ្តាល ពុំទទួលបានព័ត៌មានទីផ្សារ និងកង្វះលទ្ធភាពទទួលបាននូវធនធានផលិត។ ចំណេះដឹងផ្នែកហិរញ្ញវត្ថុនៅមានកម្រិតទាបរបស់ស្ត្រី និងសុវត្ថិភាពក្នុងការធ្វើដំណើរត្រូវបានគេកំណត់ថាជាគម្លាតយេនឌ័រដ៏សំខាន់នៅកម្ពុជា ក្នុងការឈានរកទីផ្សាររបស់ស្ត្រី[២៦] ។ ភស្តុតាងជាច្រើនក៏បានបង្ហាញថាបុរសអាចកាន់កាប់ផលិតកម្ម និងទីផ្សារដែលការធ្វើបែបនោះទំនងជាអាចទទួលបានផលចំណេញច្រើន[២៧]។

ដើម្បីផ្សព្វផ្សាយផលិតផលរបស់ពួកគាត់ ស្ត្រីជាកសិករនៅកម្ពុជាត្រូវការជាចាំបាច់នូវព័ត៌មានទីផ្សារឲ្យទាន់ពេលវេលា អាចទុកចិត្តនិងទទួលយកបាន។ កម្ចីហិរញ្ញវត្ថុ និងឥណទានក៏មានសារៈសំខាន់ផងដែរ ក្នុងការជួយឲ្យស្ត្រីជាកសិករខ្នាតតូចអាចសងថ្លៃធនធាន ឬធាតុចូល ធ្វើឲ្យប្រសើរឡើងនូវការងារកសិកម្ម និងអភិវឌ្ឍន៍សហគ្រាសខ្នាតតូចដើម្បីផ្តល់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចដល់ពួកគាត់ និងទំនុកបម្រុងគ្រួសាររបស់ពួកគេ។ សកម្មភាពជារួមនេះ អាចដើរតួនាទីយ៉ាងសំខាន់សម្រាប់ស្ត្រីជាកសិករខ្នាតតូច ក្នុងការបង្កើនផលិតភាព និងលទ្ធភាពទទួលបាននូវទីផ្សារ។ លើសពីនេះទៅទៀត គំនិតផ្តួចផ្តើមក្នុងការសម្របសម្រួលដល់លទ្ធភាពទទួលបានទីផ្សារ ត្រូវការយកចិត្តទុកដាក់ និងដោះស្រាយកត្តាប្រឈមនៃយេនឌ័រមកលើស្ត្រីជាកសិករខ្នាតតូច និងជាសហគ្រិនផ្នែកកសិ-ពាណិជ្ជកម្ម។ ដូច្នេះ ការពង្រឹងលទ្ធភាពទទួលបាននូវទីផ្សាររបស់ពួកគាត់ ទាមទារឲ្យមានការវិភាគខ្សែសង្វាក់តម្លៃ និងការធ្វើអន្តរាគមន៍ឲ្យចំគោលដៅ។

## ការចូលរួមរបស់ស្ត្រីក្នុងគំនិតផ្តួចផ្តើមលើការប្រែប្រួលអាកាសធាតុ

នៅក្នុងប្រទេសកម្ពុជាការប្រែប្រួលអាកាសធាតុត្រូវបានរំពឹងថាកាន់តែបន្ថែម និងបង្កើនភាពតានតឹងចំពោះបញ្ហាប្រឈមក្នុងការអភិវឌ្ឍដោយបន្តមានឥទ្ធិពលលើក្រុមមនុស្សក្រីក្រ និងក្រុមជនងាយរងគ្រោះជាពិសេសលើស្ត្រី និងកុមារ[២៨]។ ការប្រែប្រួលអាកាសធាតុមានឥទ្ធិពលខុសៗគ្នាទៅលើមនុស្សគ្រប់រូប ទាំងបុរស និងស្ត្រី។

---

២៥. សៀវភៅយេនឌ័រក្នុងប្រភពកសិកម្ម រៀបរៀងដោយ ធនាគារពិភពលោក និង IFAD ឆ្នាំ ២០០៩

២៦. កម្ពុជា: យេនឌ័រក្នុងការវាយតម្លៃកសិកម្ម រៀបរៀងដោយធនាគារពិភពលោក ឆ្នាំ ២០១៤ (សេចក្តីព្រាងបឋម)

២៧. ដូចលេខ២៦

២៨. ការវាយតម្លៃយេនឌ័រនៅកម្ពុជា សេចក្តីសង្ខេបគោលនយោបាយ ១០ យេនឌ័រ និងការប្រែប្រួលអាកាសធាតុ របស់ក្រសួងកិច្ចការនារី ឆ្នាំ ២០១៤

ការឆ្លើយតបរបស់ស្ត្រីទៅលើផលប៉ះពាល់ ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុក៏មានលក្ខណៈខុសៗ គ្នាដែរ ជាពិសេសនៅពេលដែលចាំបាច់ឲ្យមានការធានានូវសន្តិសុខស្បៀង និងកម្រិតជីវភាពដើម្បីដោះស្រាយបញ្ហាគ្រោះថ្នាក់ និងហានិភ័យផ្សេងៗ។ ស្ត្រីមានលទ្ធភាពតិចតួចក្នុងការទទួលបាននូវធនធានហិរញ្ញវត្ថុ ដីធ្លី ធនធានធម្មជាតិ បច្ចេកវិទ្យា ការអប់រំ និងសេវាកម្មអភិវឌ្ឍន៍ដែលមានសារៈសំខាន់សម្រាប់ការបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ ឲ្យមានប្រសិទ្ធភាព។ ស្ត្រីមិនត្រឹមតែជាអ្នកងាយរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុប៉ុណ្ណោះទេ ប៉ុន្តែគួរចងចាំថាពួកគាត់ក៏មានតួនាទីសំខាន់ជាភ្នាក់ងារដ៏មានប្រសិទ្ធភាពផងដែរក្នុងការឆ្លើយតបទៅនឹងការកាត់បន្ថយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ជារឿយៗស្ត្រីជាកសិករនៅកម្ពុជាមានចំណេះដឹង និងជំនាញដែលអាចប្រើប្រាស់បានក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ក្នុងការកាត់បន្ថយគ្រោះធម្មជាតិ និងក្នុងយុទ្ធសាស្ត្របន្សាំ។ លើសពីនេះទៅទៀត ការទទួលខុសត្រូវរបស់ស្ត្រីនៅក្នុងគ្រួសារ និងក្នុងសហគមន៍ ដែលជាអ្នកគ្រប់គ្រងធនធានគ្រួសារ និងធនធានធម្មជាតិ បានធ្វើឲ្យពួកគាត់អាចរួមចំណែកក្នុងការចិញ្ចឹមជីវិតដែលបន្សាំទៅនឹងការប្រែប្រួលបរិស្ថានយ៉ាងពិតប្រាកដ។

ដូច្នេះការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុត្រូវបញ្ជាក់ឲ្យច្បាស់ពីយេនឌ័រ ដោយមានការយល់ដឹងពីតួនាទីច្បាស់លាស់ និងសកម្មភាពរបស់ស្ត្រី និងបុរស។ គំនិតផ្តួចផ្តើមនេះត្រូវតែធានាថាស្ត្រីត្រូវបានដាក់បញ្ចូលទៅក្នុងផែនការកាត់បន្ថយនិងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ដែលត្រូវបានធ្វើឡើងក្នុងគោលបំណងពង្រឹងសន្តិសុខស្បៀង និងការលើកកម្ពស់កម្រិតជីវភាព។ ទោះបីជាយ៉ាងណាក៏ដោយ នាពេលបច្ចុប្បន្នមានការយកចិត្តទុកដាក់តិចតួចណាស់ពីរបៀបដែលបុរស និងស្ត្រីជាកសិករអាចកាត់បន្ថយហានិភ័យ និងអាចបន្សាំខ្លួនទៅនឹងបញ្ហាប្រឈម ដែលកើតមានឡើងពីការប្រែប្រួលអាកាសធាតុ។ ភាពងាយបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ គឺចាំបាច់ណាស់ត្រូវពង្រឹងចំណេះដឹង និងសមត្ថភាពរបស់ស្ត្រីជាកសិករ ដើម្បីធន់ទ្រាំនឹងភាពតានតឹងដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ (ដូចជាអាកាសធាតុប្រែប្រួលខ្លាំង ភ្លៀងធ្លាក់មិនទៀងទាត់ ការប្រែប្រួលនូវកំណកអាកាស ទឹកជំនន់ និងគ្រោះរាំងស្ងួត) នៅក្នុងវិស័យកសិកម្ម និងដោយធានាថាពួកគាត់មានលទ្ធភាពទទួលបាននូវសេវាកម្មផ្សព្វផ្សាយ។ អន្តរាគមន៍បន្ថែមលើការកាត់បន្ថយការប្រែប្រួលអាកាសធាតុដែលចាំបាច់សម្រាប់ស្ត្រីមានដូចជា៖ ការកំណត់ពីបច្ចេកវិទ្យាសម្រាប់កែច្នៃផលិតផល (ការកំដៅ ការចម្អិនអាហារ និងការសម្ងួត) ការធ្វើឲ្យត្រជាក់និងការរក្សាផលិតផល ការកែច្នៃកាកសំណល់កសិកម្ម ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នមេតាន និងការកាត់បន្ថយការប្រើប្រាស់ជីគីមី ការប្រើប្រាស់បច្ចេកវិទ្យាថាមពលកកើតឡើងវិញសម្រាប់បូមទឹក និងធារាសាស្ត្រ និងការអនុវត្តកសិកម្មឲ្យប្រសើរជាងមុនដោយរួមបញ្ចូលការគ្រប់គ្រងដីឲ្យបានល្អ និងប្រកបដោយនិរន្តរភាព។

## បញ្ហាយេនឌ័រ និងផលិតកម្មដំណាំ

ផលដំណាំគឺមានចំនួន ៦០% នៃផលិតផលកសិកម្មសរុបនៅកម្ពុជា ហើយស្រូវរួមចំណែកប្រមាណជា ៤០%។ ដំណាំសំខាន់ជាងគេនៅកម្ពុជាគឺជាដំណាំស្រូវដែលត្រូវបានដាំដុះលើផ្ទៃដីប្រមាណជា៩០% នៃដីដំណាំសរុប[២៩]។

២៩. ការធ្វើជំនួញដំណាំស្រូវដែលធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា ការវាយតម្លៃសេដ្ឋកិច្ចសង្គម និងការវិភាគយេនឌ័ររៀបរៀងដោយធនាគារពិភពលោក ឆ្នាំ ២០១២

ដំណាំស្រូវចំនួន៤ប្រភេទផ្សេងគ្នា ត្រូវបានដាំដុះពេញមួយឆ្នាំក្នុងរដូវដាំដុះចំនួន៤ ដូចជា៖ ស្រូវប្រដេញទឹក (ពាក់កណ្តាលខែធ្នូ ដល់ចុងខែមេសា) ស្រូវប្រាំង (ពាក់កណ្តាលខែមករា ដល់ចុងខែ ឧសភា) ស្រូវបង្កើនរដូវ (ពីខែឧសភា ដល់ពាក់កណ្តាលខែសីហា) និងស្រូវវស្សា (ពីខែសីហាដល់ពាក់កណ្តាលខែធ្នូ)[៣០] ។ ជាទម្លាប់ដំណាក់កាលដំបូងនៃផលិតកម្មស្រូវគឺបុរសជាអ្នករ៉ាប់រង និងដំណាក់កាលក្រោយៗមកទៀតគឺស្ត្រីជាអ្នកទទួលបន្ទុក។ បុរសបំពេញការងារជាអ្នករៀបចំដី ចំណែកឯស្ត្រីទទួលបន្ទុករៀបចំសំណាប និងកំចាត់ស្មៅ។ កិច្ចការផ្សេងៗទៀតដូចជា៖ ការដកសំណាប ការស្ទូង ការប្រមូលផល និងការងារទីផ្សារ គឺជាការងាររួមគ្នា[៣១]។ បច្ចុប្បន្ននេះតួនាទីទាំងនេះ គឺកំពុងប្រែប្រួលទៅតាមការងារកសិកម្មដែលប្រើប្រាស់កំលាំងម៉ាស៊ីន និងដោយការធ្វើចំណាកស្រុករបស់បុរសក្មេងៗចេញពីតំបន់ជនបទ។ ជាលទ្ធផលស្ត្រី ក្លាយជាអ្នកទទួលបន្ទុកក្នុងការងាររៀបចំដីស្រោចស្រព បោកបែន ជួលកម្មករ គ្រប់គ្រងកសិដ្ឋាន និងធ្វើជំនួញ។

ការរួមចំណែករបស់កសិករស្ត្រីកម្ពុជា ក្នុងការដាំដុះដំណាំបន្ទាប់បន្សំដូចជាបន្លែជាដើម គឺមានទំហំធំធេងណាស់។ ដំណាំភាគច្រើនត្រូវបានដាំនៅក្នុងសួនច្បារដំណាំក្រោយផ្ទះ ហើយដំណាំទាំងនេះបានផ្តល់នូវជីវជាតិនិងចូលរួមចំណែកដល់សន្តិសុខស្បៀងនៅក្នុងគ្រួសារ។ ដូច្នេះទីផ្សារក្នុងស្រុកក៏កាន់តែផ្តល់នូវឱកាសដល់ស្ត្រីក្នុងការរកបានចំណូលតាមរយៈការលក់បន្លែទ្រង់ទ្រាយតូច។

## បញ្ហាយេនឌ័រ និងព្រៃឈើ

ការទទួលស្គាល់តួនាទីដ៏សំខាន់របស់ស្ត្រី នៅក្នុងសកម្មភាពការងារទាក់ទងនឹងវិស័យព្រៃឈើ គឺមានការកើនឡើង។ ទោះជាយ៉ាងនេះក៏ដោយ ទំនាក់ទំនងរវាងតួនាទីបុរស និងស្ត្រីក្នុងវិស័យព្រៃឈើ និងបញ្ហាព្រៃឈើ ទាមទារឲ្យមានការយកចិត្តទុកដាក់បន្ថែមទៀត។ ការគ្រប់គ្រងព្រៃឈើ និងប្រព័ន្ធកសិ-ព្រៃឈើពុំទាន់មានអព្យាក្រិតភាពខាងយេនឌ័រនៅឡើយទេ។ បើប្រៀបធៀបជាមួយបុរស ជាញឹកញាប់ ស្ត្រីក្នុងសហគមន៍ព្រៃឈើពុំសូវទទួលបានអត្ថប្រយោជន៍ប៉ុន្មានទេដោយសារតែមូលហេតុទាក់ទងនឹងវប្បធម៌ សេដ្ឋកិច្ចនិងសង្គមកិច្ច ក្នុងការទទួលបាន និងគ្រប់គ្រងធនធានព្រៃឈើរបស់ពួកគាត់ រួមទាំងលទ្ធភាពក្នុងការទទួលបានឱកាសផ្នែកសេដ្ឋកិច្ចផងដែរ។

សកម្មភាពការងារព្រៃឈើនៅកម្ពុជាជាធម្មតាមានភាពខុសគ្នាខាងយេនឌ័រ នៅខណៈដែលបុរសជាធម្មតាចាប់អារម្មណ៍តែលើផលព្រៃឈើជាឈើប្រណិតសម្រាប់ធ្វើអាជីវកម្ម ហើយស្ត្រីទំនងជាមានទំនោរទៅលើផលព្រៃឈើដែលមិនមែនជាឈើប្រណិត (សត្វព្រៃ ផ្តៅ មើមរុក្ខជាតិ ឬស្សី រុក្ខជាតិថ្នាំ គ្រាប់រុក្ខជាតិ និងផ្សិត) សម្រាប់ផ្គត់ផ្គង់ក្នុងគ្រួសារ ដូចជាបរិភោគ និងចំណូលគ្រួសារ[៣២]។ ជាញឹកញាប់ស្ត្រីមានចំណេះដឹង និងជំនាញខ្ពស់ខាងប្រើប្រាស់ស្លឹកឈើព្រៃ និងដើមឈើព្រៃសម្រាប់គោលបំណងផ្សេងៗ និងក៏មានការយល់ដឹងច្រើនពីការងារអភិរក្សធនធានទាំងនោះ។

៣០. ការធ្វើជំនួញដំណាំស្រូវដែលធន់ទ្រាន់នឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា ការវាយតម្លៃសេដ្ឋកិច្ចសង្គម និងការវិភាគយេនឌ័ររៀបរៀងដោយធនាគារពិភពលោក ឆ្នាំ ២០១២

៣១. ដូចលេខ៣០

៣២. យេនឌ័រ និង REDD: ការវិភាគពីតំបន់អាស៊ី ឆ្នាំ ២០១០

ការយល់ដឹងទាំងនេះអាចផ្តល់នូវឱកាសល្អបំផុតសម្រាប់ការប្រើប្រាស់ចំណេះដឹង និងជំនាញរបស់ស្ត្រីក្នុងការគាំទ្រដល់សកម្មភាពកាត់បន្ថយការប្រែប្រួលអាកាសធាតុដែលពាក់ព័ន្ធទៅនឹងព្រៃឈើ ដើម្បីជួយកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងអាចបែងចែកផលចំណេញផ្នែកសេដ្ឋកិច្ច ឬផលប្រយោជន៍ជាច្រើនទៀតនាពេលអនាគត។ ស្ត្រីនៅកម្ពុជាដើរតួនាទីចំបងក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ ការកែច្នៃ និងសកម្មភាពទីផ្សារសម្រាប់អនុផលព្រៃឈើដែលមិនមែនឈើប្រណិត (NTFP)។

ទោះបីជាយ៉ាងណាក៏ដោយ តួនាទីស្ត្រីក្នុងខ្សែសង្វាក់តម្លៃព្រៃឈើ នៅមានកម្រិតនៅឡើយ និងជាទូទៅមិនសូវមានការជួយគាំទ្រ។ ខ្សែសង្វាក់តម្លៃព្រៃឈើមានសារៈសំខាន់បំផុតសម្រាប់ចំណូល និងជីវភាពរបស់ស្ត្រី។ ស្ត្រីពុំមានលទ្ធភាពដូចគ្នានឹងបុរសទេក្នុងការទទួលបានបច្ចេកវិទ្យាថ្មីៗ ឥណទាន វគ្គបណ្តុះបណ្តាលសមស្រប ទីផ្សារ និងការធ្វើសេចក្តីសម្រេចចិត្ត ។

## បញ្ហាយេនឌ័រ និងផលិតកម្មដំណាំកៅស៊ូ

រាជរដ្ឋាភិបាលកម្ពុជា មានការប្តេជ្ញាយ៉ាងមុតមាំចំពោះការលើកកម្ពស់ការដាំដំណាំកសិ-ឧស្សាហកម្មដែលរួមមាន សម្បទានដីសេដ្ឋកិច្ច និងការអភិវឌ្ឍដំណាំកៅស៊ូ។ ផលិតកម្មដំណាំកៅស៊ូបានកើនឡើងយ៉ាងខ្លាំង និងរឹងមាំនៅក្នុងប្រទេសកម្ពុជា ដោយសារតែការកើនឡើងទាំងតម្លៃ និងតម្រូវការអន្តរជាតិ ជាមួយនឹងសក្តានុពលនៃលក្ខខណ្ឌដីដ៏សមស្រប ព្រមទាំងក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ។ នៅកម្ពុជា ចំការកៅស៊ូអាចត្រូវបានបែងចែកជាបីប្រភេទ គឺចំការកៅស៊ូរដ្ឋ ចំការកៅស៊ូជាលក្ខណៈគ្រួសារ និងចំការកៅស៊ូឯកជន ដែលមានលក្ខណៈជាឧស្សាហកម្ម។

បច្ចុប្បន្នស្ត្រី៥០% បានបំពេញការងារជាកម្មករនៅផ្នែកផលិតកម្មនិងកែច្នៃកៅស៊ូ ដែលក្នុងនោះមាន ២៦% ជាកម្មករជៀជ័រកៅស៊ូ។ អភិក្រមដែលមានលក្ខណៈជាប្រព័ន្ធជាមួយនឹងការណែនាំនូវការងារសមស្របនៅជនបទ ការពង្រឹងសមាគមស្ត្រី និងសិទ្ធិការងារដែលឆ្លើយតបនឹងយេនឌ័រ (លទ្ធភាពនៃការទទួលបានការងារប្រាក់កំរៃស្មើគ្នា និងការអភិវឌ្ឍសមត្ថភាពស្មើគ្នា) អាចដើរតួជាផ្នែកមួយយ៉ាងសំខាន់ក្នុងការគាំទ្រភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ក្នុងអនុវិស័យកៅស៊ូ និងបង្កើនការចូលរួម និងភាពជាតំណាងយ៉ាងសកម្មរបស់ពួកគេ។

## បញ្ហាយេនឌ័រ និងផលិតកម្មសត្វ

ស្ត្រីជនបទនៅកម្ពុជាភាគច្រើនចូលរួមក្នុងការចិញ្ចឹមសត្វខ្នាតតូចដូចជា បក្សី (មាន់ និងទា) និងជ្រូកដែលជាប្រភពអាហារដ៏សំខាន់ និងជាចំណូលបន្ថែមសម្រាប់គ្រួសារ។ សម្រាប់ស្ត្រីក្រីក្រ ការចិញ្ចឹមសត្វដើរតួជាចំបងក្នុងការសន្សំប្រាក់ ក៏ដូចជាសម្រាប់ការរ៉ាប់រងចំពោះគ្រោះថ្នាក់ផ្សេងៗ ជំងឺ មរណភាព និងចំពោះគ្រោះធម្មជាតិ ដូចជាគ្រោះរាំងស្ងួតជាដើម។

ស្ថិតិជាតិបានបង្ហាញថាភាគច្រើន នៃស្ត្រី (៧០%) និងបុរស (៧៤%) ជាមេគ្រួសារ ចូលរួមក្នុងការចិញ្ចឹមមាន់។ តម្លៃលក់សត្វពាហនៈ និងបក្សីទាំងអស់ ដែលចិញ្ចឹមដោយគ្រួសារដែលមានស្ត្រីជាមេគ្រួសារមានចំនួនសរុប ១៧៥ ពាន់លានរៀល ឬ ៤៣ លានដុល្លារ ដែលជាមធ្យមស្មើទៅនឹង ៤២៤ ពាន់រៀលក្នុងមួយគ្រួសារ។ នៅពេលដំណាលគ្នានេះដែរ កសិករដែលមានបុរសជាមេគ្រួសារលក់សត្វពាហនៈ និងបក្សីដែលមានទឹកប្រាក់សរុបចំនួន ១៣០០ ពាន់លានដុល្លារ ឬ ៣១៣ លានដុល្លារ ដែលជាមធ្យមស្មើទៅនឹង ៧៩៤ ពាន់រៀលក្នុងមួយគ្រួសារ[៣៣]។

ថ្វីបើស្ត្រីបានចូលរួមយ៉ាងច្រើនក្នុងការគ្រប់គ្រងការចិញ្ចឹមសត្វក៏ដោយ ជាញឹកញាប់ពួកគាត់មិនសូវទទួលបាននូវសេវាកម្ម ព័ត៌មាននិងធនធាននានា ហើយមានតួនាទីតិចតួចណាស់ក្នុងការធ្វើជំនួញដែលទាក់ទងនឹងសត្វ និងផលិតផលសត្វ។ ជារឿយៗបញ្ហានេះកើតឡើងមកពីកង្វះលទ្ធភាពក្នុងទទួលបានធនធាន និងទីផ្សារ រួមផ្សំជាមួយនឹងការចេះអក្សរនៅមានកម្រិត និងកត្តារារាំងដល់ការធ្វើដំណើរទៅឆ្ងាយ។ ការកំណត់អត្តសញ្ញាណ និងការគាំទ្រដល់តួនាទីស្ត្រីឲ្យក្លាយជាម្ចាស់កសិដ្ឋានចិញ្ចឹមសត្វ ជាអ្នកថែទាំសត្វ ជាអ្នកប្រមូលទិញវត្ថុធាតុដើម ជាអ្នកផលិត ជាអ្នកប្រើប្រាស់ និងជាអ្នកលក់ចំណីសត្វ ទាំងអស់នេះ គឺជាកត្តាគន្លឹះក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ស្ត្រី។ ការគាំទ្រនេះមានដូចជា លទ្ធភាពទទួលវត្ថុធាតុដើមល្អៗ (ចំណីសត្វ) បច្ចេកវិទ្យាថ្មីៗ សេវាកម្មពេទ្យសត្វ (ការធ្វើវ៉ាក់សាំង និងការតាមដានជំងឺសត្វ) ឥណទាន ព័ត៌មានទីផ្សារ និងធនធានសម្រាប់ទុកដាក់ (ទ្រុង របង និងសំណាញ់) មាន់ ទា និងជ្រូកឲ្យបានប្រសើរជាងមុន។ លើសពីនេះទៅទៀត នៅពេលដែលអនុវិស័យផលិតកម្មសត្វនៅកម្ពុជាបានជួបប្រទះនឹងកំណែទម្រង់ទីផ្សារយ៉ាងឆាប់រហ័ស អ្នកចិញ្ចឹមសត្វដែលមានជីវភាពក្រីក្រ ជាពិសេសស្ត្រីអាចប្រឈមនឹងកត្តារារាំងដែលមិនអាចបំពេញទៅបានតាមបទបញ្ជាជាច្រើនដែលកំណត់ដោយទីផ្សារ ឧទាហរណ៍ដូចជា ស្តង់ដាអនាម័យ ការដឹកជញ្ជូនសត្វ និងស្តង់ដាកន្លែងរក្សាសត្វ ជាដើម។

## បញ្ហាយេនឌ័រ និងជលផល

ជលផល ដែលរួមមានវារីវប្បកម្ម កំពុងមានការលូតលាស់យ៉ាងឆាប់រហ័សបំផុតនៅក្នុងវិស័យកសិកម្ម ហើយជាប្រភពសំខាន់សម្រាប់ជីវភាព និងផ្តល់នូវសន្តិសុខស្បៀង និងជីវជាតិដល់គ្រួសារទាំងមូល រួមទាំងមីក្រូជីវជាតិដែលចាំបាច់សម្រាប់ស្ត្រី និងកុមារ។ នៅកម្ពុជា ស្ត្រីបានដើរតួនាទីយ៉ាងសំខាន់ក្នុងវិស័យជលផល និងទំហំនៃការចូលរួមរបស់ស្ត្រីនៅក្នុងខ្សែសង្វាក់តម្លៃវារីវប្បកម្ម គឺមានវិសាលភាពធំធេងណាស់។ ទិន្នន័យមួយបានអះអាងថា ការចូលរួមរបស់ស្ត្រីនៅក្នុងការចិញ្ចឹមត្រី នៅជុំវិញបឹងទន្លេសាបមានចំនួនចាប់ពី៥០% និងកើនដល់ ៨៥% នៅក្នុងផលិតកម្ម ការកែច្នៃ ទីផ្សារ និងការធ្វើជំនួញត្រី[៣៤]។ ស្ត្រីគ្រប់គ្រងអាជីវកម្មលក់រាយត្រីតូចៗដែលចាប់មកពីបឹងទន្លេសាប និងពីស្រែស្ទើរតែទាំងអស់។ ត្រីទាំងនេះត្រូវបានលក់នៅទីផ្សារក្នុងស្រុក ឬលក់ជាខ្នាតតូចទៅឲ្យឈ្មួញកណ្តាល[៣៥]។

---

៣៣. ជំនួញភាវូនីយកម្មដំណាំស្រូវដែលធន់នឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា: ការវាយតម្លៃសេដ្ឋកិច្ចសង្គម និងការវិភាគយេនឌ័រ រៀបរៀងដោយ ធនាគារពិភពលោក ឆ្នាំ ២០១២

៣៤. យេនឌ័រ និងវារីវប្បកម្ម: ការបែងចែកអត្ថប្រយោជន៍ឲ្យបានស្មើភាពគ្នា រៀបរៀងដោយ មជ្ឈមណ្ឌលត្រីពិភពលោក ឆ្នាំ ២០១១

៣៥. បញ្ហាយេនឌ័រក្នុងការចិញ្ចឹមត្រីខ្នាតតូចនៅអាស៊ី: ស្ត្រីជាប្រភពដ៏សំខាន់នៃព័ត៌មាន ក្សូតូ គូសាកាបេ

ការកែច្នៃត្រីធ្វើជាប្រហុក ទឹកត្រី ត្រីឆ្អើរនិងត្រីងៀត និងការកែច្នៃកំពិស គឺជាសកម្មភាពសាមញ្ញរបស់ស្ត្រីនៅក្នុងភូមិជុំវិញបឹងទន្លេសាប[៣៦]។ ជាទូទៅ ក្នុងគ្រួសារដែលមានជីវភាពក្រីក្រ ស្ត្រី និងកុមារគឺជាកម្លាំងពលកម្មដ៏ចំបងសម្រាប់សកម្មភាពកែច្នៃត្រី[៣៧]។ លើសពីនេះទៅទៀត ស្ត្រីបានចូលរួមក្នុងការស្វែងរកនុយត្រី ដងសន្ទូច តំឡើងនិងថែទាំឧបករណ៍នេសាទ ដូចជាមង អួន និងខ្សែសន្ទូចជាដើម ចំណែកឯបុរស ជាអ្នកនេសាទផ្ទាល់តែម្តង។ ជាការងារបន្ថែមនៅក្នុងអំឡុងពេលមានទឹកជំនន់ ស្ត្រីក៏ចូលរួមនេសាទត្រីនៅក្បែរៗផ្ទះដោយប្រើប្រាស់ដងសន្ទូច និងផ្លែសន្ទូច[៣៨]។

ទោះបីជាមានភស្តុតាងយ៉ាងច្បាស់ថាបុរស និងស្ត្រីកម្ពុជា បានចូលរួមក្នុងវិស័យជលផលក៏ដោយ ក៏ការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យនេះត្រូវបានគេមើលរំលង។ ស្ត្រីត្រូវបានគេបញ្ចៀសពីការផ្ទេរបច្ចេកទេសជលផល និងវារីវប្បកម្ម មានលទ្ធភាពតិចតួចក្នុងការទទួលបានធនធានសំខាន់ៗដូចជា ឥណទាន និងសេវាកម្មផ្សព្វផ្សាយ ហើយនៅតែមិនត្រូវបានគេបញ្ចូលទៅក្នុងខ្សែសង្វាក់តម្លៃខ្នាតធំ។ ស្ត្រីមានវត្តមាន និងឥទ្ធិពលតិចតួចណាស់ នៅក្នុងគណៈកម្មាធិការគ្រប់គ្រងសហគមន៍ជលផល។ ការបញ្ចប់គម្លាតយេនឌ័រក្នុងការទទួលបានធនធានសំខាន់ៗជាមួយនឹងការបង្កើតគំនិតផ្តួចផ្តើមរួមគ្នា (ក្រុមស្ត្រីជាអ្នកផលិត) អាចជួយបង្កើននូវផលិតភាព ប្រាក់ចំណូល សន្តិសុខស្បៀង និងខ្សែចង្វាក់តម្លៃវារីវប្បកម្មសម្រាប់ស្ត្រីក្នុងវិស័យជលផល។ សកម្មភាពរួមគ្នាគឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពសម្រាប់បង្កើនផលិតភាព និងលទ្ធភាពទទួលបាននូវទីផ្សារនៅខណៈពេលដែលមានការចែករំលែកចំណេះដឹង ព័ត៌មាន និងធនធានសម្រាប់ការផលិត ដូចជា៖ ឧបករណ៍ទំនើបៗ ឃ្លាំងមធ្យោបាយដឹកជញ្ជូន អជ្ញាប័ណ្ណ និងឥណទាន។ យន្តការគាំទ្ររួម ដូចជាក្រុមអ្នកផលិត ក្រុមសន្សំប្រាក់និងសហគមន៍ទីផ្សារ ជួយកសិករជាស្ត្រីតាមរយៈកម្រិតសេដ្ឋកិច្ច អំណាចក្នុងការចរចារ សម្របសម្រួលលទ្ធភាពក្នុងការទទួលបាននូវសេវាកផ្សព្វផ្សាយ និងពង្រឹងសម្លេងស្ត្រីក្នុងផ្នែកនយោបាយ។ សិទ្ធិអំណាចរបស់ស្ត្រីត្រូវបានពង្រឹងជាពិសេសតាមរយៈក្រុមទាំងនោះ ដោយពួកគេត្រូវបានផ្តល់នូវឱកាសចូលរួមក្នុងការធ្វើការសម្រេចចិត្ត និងតួនាទីជាអ្នកដឹកនាំ។

## ៤.ទស្សនវិស័យ បេសកកម្ម និងគោលដៅរួម

**ទស្សនវិស័យ៖**គាំទ្រការលើកកម្ពស់សមភាពយេនឌ័រ និងភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីកម្ពុជាតាមរយៈការចូលរួមយ៉ាងសកម្ម និងភាពជាតំណាងរបស់ស្ត្រីនិងបុរសសម្រាប់ឱកាសរួមចំណែកនិងទទួលបានផលប្រយោជន៍ពីកំណើនសេដ្ឋកិច្ចកសិកម្ម ផ្អែកលើអភិក្រមប្រកបដោយប្រសិទ្ធភាពលើផលិតភាព ពិពិធកម្មខ្សែសង្វាក់តម្លៃ ពាណិជ្ជូបណីយកម្ម និងការអភិរក្សនិងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

៣៦. គម្រោងកែច្នៃត្រីរបស់ស្ត្រី លក្ខណៈនៃកិច្ចសន្យា រៀបរៀងដោយCambodia Harvest Program USAID
៣៧. ដូចលេខ ៣៦
៣៨. ការពង្រឹងតួនាទីស្ត្រីក្នុងការចិញ្ចឹមត្រី ដោយ ធនាគារអភិវឌ្ឍន៍អាស៊ី ឆ្នាំ ២០០៧

**បេសកកម្ម៖** ពង្រឹងឥទ្ធិពលរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទលើសមភាពយេនឌ័រ នៅក្នុងគ្រប់វិស័យការងារ-ការកាត់បន្ថយភាពក្រីក្រ សន្តិសុខស្បៀង ផលិតកម្មកសិកម្ម ការផ្លាស់ប្តូរចំណេះដឹង ការស្រាវជ្រាវនិងគុណភាពសេវាផ្សព្វផ្សាយ និងការបន្ថែមតម្លៃលើការឆ្លើយតបយេនឌ័រ ដែលជាមូលដ្ឋានដ៏មានប្រសិទ្ធភាពនិងសមធម៌មលើវិស័យកសិកម្ម។

**គោលដៅរួម៖** ធានានូវការបញ្ជ្រាបទស្សនៈ ការវិភាគ ក្បួនខ្នាត បទដ្ឋាន និងអភិក្រមយេនឌ័រនៅក្នុងការងាររបស់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅគ្រប់កំរិត។

## ៥. គោលបំណងជាយុទ្ធសាស្ត្រ

**គោលបំណងទី១៖** លើកកម្ពស់សិទ្ធអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីតាមរយៈលទ្ធភាពស្ត្រី ក្នុងការទទួលបានទំនិញ និងសេវាកម្មសម្រាប់ការអភិវឌ្ឍកសិកម្ម និងទីផ្សារកសិកម្ម។

**លទ្ធផល៖**[៣៩]

១. ស្ត្រីមានលទ្ធភាពកាន់តែប្រសើរក្នុងការទទួលបាននូវធនធានកសិកម្ម

២.ស្ត្រីមានលទ្ធភាពកាន់តែល្អក្នុងការទទួលបាននូវព័ត៌មាន ចំណេះដឹង និងសេវាកម្មជំនាញបច្ចេកទេសដើម្បីគាំទ្រដល់ការងាររបស់ពួកគាត់ក្នុងវិស័យកសិកម្ម ដូចជា៖ ប្រពលវប្បកម្មដំណាំ និងពិពិធកម្មដំណាំ វារីវប្បកម្ម ការចិញ្ចឹមសត្វ ព្រៃឈើ និងកៅស៊ូ និងឱកាសផ្សេងៗដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ

៣.ស្ត្រីមានបណ្តាញកាន់តែរឹងមាំ ជាមួយនឹងទីផ្សារបែបប្រពៃណី និងទីផ្សារថ្មីៗ ។

**គោលបំណងទី២៖** ពង្រឹងសមត្ថភាព ធនធាន និងការប្តេជ្ញាចិត្តរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីធានានូវប្រសិទ្ធិភាពនៃការបញ្ជ្រាបយេនឌ័រទៅក្នុងវិស័យកសិកម្ម

**លទ្ធផល៖**[៤០]

១. តម្រូវការ និងកង្វល់របស់ស្ត្រី ក៏ដូចជាបុរសត្រូវបានដាក់បញ្ចូលទៅក្នុងគ្រប់គោលនយោបាយលិខិតបទដ្ឋាន និងក្របខ័ណ្ឌច្បាប់

២. បញ្ហាយេនឌ័រត្រូវបានបញ្ចូលទៅក្នុងការរៀបចំផែនការ ការអនុវត្ត ការតាមដាន និងការវាយតម្លៃលើគ្រប់សកម្មភាព សេវាកម្មបច្ចេកទេស គម្រោង កម្មវិធី និងថវិកា

៣. ក្រុមការងារយេនឌ័រ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសមត្ថភាព ជំនាញច្បាស់លាស់ និងធនធាន សម្រាប់អនុវត្តការងារ ការតស៊ូមតិ ការកសាងចំណេះដឹង ភាពជាដៃគូ ជំនួយការបច្ចេកទេស និងតួនាទីត្រួតពិនិត្យ។

៣៩. តារាងសូចនាករដាក់ក្នុងឧបសម្ព័ន្ធ
៤០. តារាងសូចនាករដាក់ក្នុងឧបសម្ព័ន្ធ

**គោលបំណងទី៣៖** បង្កើនភាពជាតំណាង និងការចូលរួមស្មើភាពគ្នាទាំងបុរស និងស្ត្រីក្នុងវិស័យកសិកម្ម
**លទ្ធផល៖**[៤១]

១. វត្តមាន និងឥទ្ធិពលរបស់ស្ត្រីក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានការកើនឡើង
២. វត្តមាន និងឥទ្ធិពលរបស់ស្ត្រី ក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងក្រុមគ្រប់គ្រងធនធានធម្មជាតិ និងកសិកម្មក្នុងសហគមន៍មានការកើនឡើង
៣. ស្ត្រីកាន់តែមានលទ្ធភាពទទួលបានឱកាសអភិវឌ្ឍន៍ជំនាញ និងការសិក្សា ដើម្បីគាំទ្រដល់ការចូលរួមរបស់ពួកគាត់ក្នុងវិស័យកសិកម្ម រួមមានផលិតកម្មដំណាំ ការចិញ្ចឹមសត្វ ជលផល ព្រៃឈើ និងកៅស៊ូ។

## ៦. ការអនុវត្ត

ការយល់ដឹងពីសារៈសំខាន់នៃការបញ្ជ្រាបយេនឌ័រ គឺជាជំហានដ៏សំខាន់ក្នុងការបង្វែរការចាប់អារម្មណ៍ទៅលើតួនាទីខុសៗគ្នា ទំនួលខុសត្រូវ តម្រូវការ និងបញ្ហាប្រឈមរបស់បុរស និងស្ត្រីក្នុងវិស័យកសិកម្ម។ ទោះជាយ៉ាងណាក៏ដោយ ការប្រែក្លាយការយល់ដឹងនេះ ឲ្យទៅជាសកម្មភាពជាស្តែងនៅតែជាការប្រឈមយ៉ាងធំសម្រាប់ថ្នាក់ដឹកនាំនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ត្រីបច្ចេកទេស សមាជិកក្រុមការងារយេនឌ័រ និងកុមារ និងជនបង្គោលយេនឌ័រ និងកុមារ នៅគ្រប់អនុវិស័យ និងគ្រប់កម្រិត។ ការអនុវត្តទាមទារឲ្យមានការប្តេជ្ញាចិត្តខ្ពស់ គណនីភាព និងធនធានមនុស្ស រួមទាំងធនធានហិរញ្ញវត្ថុ។ គោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ គឺជាភស្តុតាងមួយដែលបញ្ជាក់ពីការប្តេជ្ញាចិត្តនេះ។ ការអភិវឌ្ឍសមត្ថភាពក្រុមការងារយេនឌ័រ និងកុមារឲ្យកាន់តែខ្លាំង គឺជាចំណុចចាប់ផ្តើមនៃដំណើរការបញ្ជ្រាបយេនឌ័រ និងការផ្តល់ធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ គឺជាជំហានដំបូងបង្អស់ក្នុងដំណើរការអនុវត្ត។ លើសពីនេះទៅទៀតទាមទារឲ្យមានការបង្កើតឡើងនូវយន្តការគ្រប់គ្រាន់ សម្រាប់ការត្រួតពិនិត្យភាពរីកចម្រើននេះ។

ទំនួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ គឺអាស្រ័យលើថ្នាក់ដឹកនាំរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ (ការិយាល័យ នាយកដ្ឋាន និងរដ្ឋបាល) នៃអនុវិស័យក្នុងវិស័យកសិកម្មគ្រប់កម្រិត នៅខណៈដែលក្រុមការងារយេនឌ័រ និងកុមារ នឹងដើរតួនាទីសំខាន់ក្នុងដំណើរការនេះ។ ក្រុមការងារយេនឌ័រ និងកុមារ នឹងទទួលខុសត្រូវលើ៖ ក) ការធ្វើផែនការសកម្មភាពបញ្ជ្រាបយេនឌ័រប្រចាំឆ្នាំ ខ) ការធ្វើសមាហរណកម្ម ផែនការបញ្ជ្រាបយេនឌ័រប្រចាំឆ្នាំទៅក្នុងផែនការប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គ) ការស្វែងរកការគាំទ្រពីដៃគូសហការ និងអ្នកពាក់ព័ន្ធនានា ឃ) ការសម្របសម្រួលលើការអនុវត្តផែនការសកម្មភាព ង) ការកសាង និងអនុវត្តសមត្ថភាព ក្នុងការធ្វើអន្តរាគមន៍ ច) ការរៀបចំរបាយការណ៍វឌ្ឍនភាព ដើម្បីបង្ហាញជូនក្រុមការងារបច្ចេកទេសតាមវិស័យ និងក្រុមការងារបច្ចេកទេសយេនឌ័រ។

៤១. តារាងសូចនាករដាក់ក្នុងឧបសម្ព័ន្ធ

ជំហានជាយុទ្ធសាស្ត្រខាងក្រោម គឺជាគន្លឹះដ៏សំខាន់ក្នុងការអនុវត្តគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម (២០១៥-២០១៨) ប្រកបដោយប្រសិទ្ធភាព របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៖

១. **ការបង្កើតស្តង់ដាយេនឌ័រ៖** មន្ត្រីរាជការ និងអ្នកអនុវត្តនៅតាមការិយាល័យ នាយកដ្ឋាន និងរដ្ឋបាលនានានៃគ្រប់អនុវិស័យនឹងមិនអាចបំពេញការងារឲ្យមានប្រសិទ្ធភាពនោះទេ ប្រសិនបើពុំមានពត៌មាន និងគោលការណ៍ណែនាំច្បាស់លាស់អំពីអ្វីទៅជាការបញ្ជ្រាបយេនឌ័រ ឬថាតើវាមានទំនាក់ទំនងទៅនឹងការងារយ៉ាងដូចម្តេច។ ដូច្នេះគួរតែមានសៀវភៅណែនាំសមស្រប និងបញ្ជីត្រួតពិនិត្យការងារជាក់ស្តែង ដែលផ្តល់ការណែនាំអំពីរបៀបវិភាគលើតម្រូវការខុសៗគ្នានៃយេនឌ័រ សកម្មភាពជាក់លាក់ក្នុងការបញ្ជ្រាបសមភាពយេនឌ័រទៅក្នុងអនុវិស័យ (ជលផល ដំណាំ សត្វ និងព្រៃឈើ) ក៏ដូចជាសកម្មភាពផ្សព្វផ្សាយកសិកម្ម និងជាពិសេសអំពីការប្រើប្រាស់សូចនាករ សម្រាប់វាស់វែងភាពរីកចម្រើននៃការបញ្ជ្រាបយេនឌ័រ។

២. **ការកសាងសមត្ថភាព៖** ត្រូវមានកិច្ចប្រឹងប្រែងរួមគ្នា ដើម្បីកសាងចំណេះដឹង និងជំនាញអំពីការបញ្ជ្រាបយេនឌ័រ លើមុខវិជ្ជាបច្ចេកទេស និងពីរបៀបបញ្ចូលកិច្ចការទាំងនេះទៅក្នុងការងារប្រចាំថ្ងៃឲ្យមានប្រសិទ្ធភាព។ ការងារនេះមានសារៈសំខាន់ណាស់ក្នុងការជួយឲ្យក្រុមការងារយេនឌ័រនិងកុមារ និងមន្ត្រីនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចទ្រទ្រង់ ទទួលយកបាន និងពង្រីកសមត្ថភាពរបស់ពួកគាត់ ដើម្បីដឹកនាំដំណើរការបញ្ជ្រាបយេនឌ័រនៅក្នុងនាយកដ្ឋាន និងអនុវិស័យ។ ការគាំទ្រនឹងអាចធ្វើឡើងក្នុងទម្រង់ជាវគ្គបណ្តុះបណ្តាលឲ្យចំគោលដៅ ការបណ្តុះបណ្តាលនៅនឹងកន្លែងការងារ ការចុះកម្មសិក្សានៅមូលដ្ឋាន ទស្សនកិច្ចសិក្សា ការហ្វឹកហាត់ការងារជាមួយស្ថាប័នជំនាញ ក៏ដូចជាជំនួយការបច្ចេកទេស។ ជាការចាំបាច់ណាស់ក្នុងការពង្រឹងសមត្ថភាពសមាជិកក្រុមការងារយេនឌ័រនិងកុមារ និងជនបង្គោលយេនឌ័រ ដើម្បីធ្វើការវិភាគយេនឌ័រ និងរៀបចំផែនការថវិកា ដែលឆ្លើយតបនឹងយេនឌ័រ និងអភិវឌ្ឍន៍វិធីសាស្ត្រនិងឧបករណ៍ចាំបាច់នានា ក្នុងការដើរតួនាទីជាកត្តាលីករលើការបញ្ជ្រាបយេនឌ័រទូទាំងវិស័យនេះ។

៣. **ការត្រួតពិនិត្យ និងគណនីភាពយេនឌ័រ៖** បញ្ហាប្រឈមដែលជួបប្រទះកន្លងមកក្នុងដំណើរការអនុវត្ត និងបញ្ជ្រាបយេនឌរ័ និងបណ្តាញយ៉ាងទូលំទូលាយនៃអ្នកដែលដើរតួនាទី និងអ្នកពាក់ព័ន្ធក្នុងវិស័យកសិកម្ម ទើបតម្រូវឲ្យមានដំណើរការដែលមានរចនាសម្ព័ន្ធត្រឹមត្រូវ ដែលអាចជួយកត់ត្រាភាពរីកចម្រើនធៀបទៅនឹងគោលបំណង។ ដំណើរការដែលមានរចនាសម្ព័ន្ធច្បាស់លាស់នេះ នឹងត្រូវធ្វើឡើងតាមរយៈការបង្កើតប្រព័ន្ធតាមដាន និងវាយតម្លៃយេនឌ័រ។ នៅក្នុងបរិបទនេះ ដើម្បីកត់ត្រា និងត្រួតពិនិត្យភាពរីកចម្រើនឲ្យបានប្រសើរទៅតាមសូចនាករ ដែលបានកំណត់ ជាការចាំបាច់ណាស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូអភិវឌ្ឍន៍របស់ខ្លួន ត្រូវចាប់ផ្តើមប្រមូលទិន្នន័យគោលជាជំហានដំបូងក្នុងការអនុវត្តគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រប្រកបដោយប្រសិទ្ធភាព។

៤. **ការកសាងភាពជាដៃគូ៖** ការកសាងភាពជាដៃគូក្នុងចំណោមអ្នកពាក់ព័ន្ធ ដូចជា៖ អង្គការសិទ្ធិស្ត្រី ដៃគូអភិវឌ្ឍន៍ ក្រសួងកិច្ចការនារី និងអ្នកពាក់ព័ន្ធដទៃទៀត ដែលមានគោលបំណង លទ្ធផលជាក់លាក់ និងកិច្ចខិតខំរួមគ្នា អាចធ្វើឲ្យសម្រេចបាននូវគោលដៅសមភាពយេនឌ័រ និងការអនុវត្តគោលនយោបាយនិងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម។ កិច្ចការទាំងនេះ នឹងជួយសម្រួលដល់ការខិតខំប្រឹងប្រែងរួមគ្នា លើការងារបញ្ជ្រាបយេនឌ័រទៅក្នុងប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃដែលមានស្រាប់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការប្រមូលទិន្នន័យបែងចែកតាមភេទ ការចែករំលែកព័ត៌មាននិងចំណេះដឹង ការចងក្រងឯកសារស្តីពីការអនុវត្តល្អៗ និងការកំណត់នូវការសិក្សា និងការស្រាវជ្រាវដែលពាក់ព័ន្ធនានា។

# ឧបសម្ព័ន្ធ ៖ តារាងលទ្ធផល និងសូចនាករ

| គោលបំណងទី១៖ លើកកម្ពស់សិទ្ធអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីតាមរយៈលទ្ធភាពស្ត្រី ក្នុងការទទួលបានទំនិញ និងសេវាកម្មសម្រាប់ការអភិវឌ្ឍ និងទីផ្សារកសិកម្ម | | | |
|---|---|---|---|
| លទ្ធផល | សូចនាករ | មធ្យោបាយផ្ទៀងផ្ទាត់ | ទិន្នន័យគោល |
| ១.ស្ត្រីមានលទ្ធភាពកាន់តែប្រសើរក្នុងការទទួលបាននូវធនធានកសិកម្ម | ១. ភាគរយស្ត្រី និងបុរស ដែលប្រើប្រាស់ធនធាន/ធាតុចូលកសិកម្មដែលល្អជាងមុន (គ្រាប់ពូជមានគុណភាពខ្ពស់ ថ្នាំពុលកសិកម្ម និងជីដែលមានការអនុញ្ញាតត្រឹមត្រូវ និងកូនត្រីពូជដែលមានគុណភាពល្អ ។ល។) | នឹងត្រូវបានកំណត់ | នឹងត្រូវបានកំណត់ |
| | ២. ភាគរយស្ត្រី និងបុរស ដែលមានលទ្ធភាពទទួលបានប្រាក់សន្សំ និងកម្ចីឥណទាន (មីក្រូហិរញ្ញវត្ថុ) | នឹងត្រូវបានកំណត់ | ឯកសារជាតិស្តីពីយេនឌ័រនៃគ្រួសារប្រកបរបរកសិកម្ម (២០១០) |
| | ៣.ភាគរយស្ត្រី និងបុរសជាម្ចាស់កម្មសិទ្ធ និងប្រើប្រាស់ឧបករណ៍គ្រឿងយន្ត និងបច្ចេកវិទ្យាថ្មីៗសម្រាប់ផលិតកម្មដំណាំ នេសាទ ការប្រមូលផល និងកែច្នៃ | នឹងត្រូវបានកំណត់ | ឯកសារជាតិស្តីពីយេនឌ័រនៃគ្រួសារប្រកបរបរកសិកម្ម (២០១០) |
| | ៤. ភាគរយស្ត្រី និងបុរសដែលជាម្ចាស់កម្មសិទ្ធ និងគ្រប់គ្រងជំនួញ (កសិកម្ម ជលផល ផលិតកម្មសត្វ ព្រៃឈើ) ធុនតូច និងមធ្យមនៅគ្រប់កម្រិត (ស្រុក ខេត្ត និងជាតិ) | នឹងត្រូវបានកំណត់ | នឹងត្រូវបានកំណត់ |
| | ៥. ភាគរយស្ត្រី និងបុរសវ័យក្មេងដែលជាម្ចាស់កម្មសិទ្ធ និងគ្រប់គ្រងជំនួញ (ធុនតូច និងមធ្យម) ជាអ្នកផ្គត់ផ្គង់ធនធាន/ធាតុចូល ឧបករណ៍សម្ភារៈ ជី ។ល។ នៅគ្រប់កម្រិត (ស្រុក ខេត្ត និងជាតិ) | នឹងត្រូវបានកំណត់ | នឹងត្រូវបានកំណត់ |

| | | | |
|---|---|---|---|
| | ៦.ចំនួននៃសកម្មភាពផ្តួចផ្តើមដើម្បីគាំទ្រ ដល់សហគ្រិនភាពរបស់ស្ត្រីវ័យក្មេងនៅគ្រប់កម្រិត (ភូមិ ស្រុក ខេត្ត និងជាតិ) នៅក្នុងការចាប់ផ្តើមសហគ្រាសកសិ-ពាណិជ្ជកម្ម ផលិតកម្មសត្វ ព្រៃឈើ និងនេសាទ | នឹងត្រូវបានកំណត់ | នឹងត្រូវបានកំណត់ |
| ២.ស្រីកាន់តែមានលទ្ធភាពក្នុងការទទួលបាននូវ ព័ត៌មាន ចំណេះដឹង និងសេវាកម្មជំនាញបច្ចេកទេសដើម្បីគាំទ្រដល់ការងាររបស់ពួកគាត់ក្នុងវិស័យកសិកម្ម ដូចជា៖ ប្រពលវប្បកម្ម ដំណាំ និងពិពិធកម្មដំណាំ វារីវប្បកម្ម ការចិញ្ចឹមសត្វ ព្រៃឈើ និងកៅស៊ូ និងឱកាសផ្សេងៗដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ១.ភាគរយស្ត្រី និងបុរស ដែលបានអនុវត្តបច្ចេកទេសថ្មីៗ និងការអនុវត្តល្អៗសម្រាប់គាំទ្រដល់ផលិតកម្មដូចជា ការដាំដុះស្រូវ ជលផល (វារីវប្បកម្ម) សាកវប្បកម្ម ព្រៃឈើ និងការចិញ្ចឹមសត្វ | នឹងត្រូវបានកំណត់ | នឹងត្រូវបានកំណត់ |
| | ២.ភាគរយស្ត្រី និងបុរស ដែលមានជំនាញ និងប្រើប្រាស់បច្ចេកវិទ្យាថ្មីៗសម្រាប់ការងារក្រោយប្រមូលផល និងការកែច្នៃក្នុងផលិតកម្មស្រូវ ជលផល (វារីវប្បកម្ម) ព្រៃឈើ សាកវប្បកម្ម និងផលិតកម្មសត្វ | នឹងត្រូវបានកំណត់ | នឹងត្រូវបានកំណត់ |
| | ៣. ភាគរយស្ត្រី និងបុរស ដែលមានជំនាញផ្នែកហិរញ្ញវត្ថុ និងការអភិវឌ្ឍន៍សហគ្រាសដើម្បីគាំទ្រការងារកសិកម្មឲ្យទៅជាជំនួញ | នឹងត្រូវបានកំណត់ | នឹងត្រូវបានកំណត់ |
| | ៤. ភាគរយស្ត្រី និងបុរស ដែលបានចូលរួមវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសកសិកម្ម ដែលរៀបចំឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ វិស័យឯកជន និងអង្គការអភិវឌ្ឍន៍នានា | នឹងត្រូវបានកំណត់ | នឹងត្រូវបានកំណត់ |
| | ៥.ចំនួនវគ្គបណ្តុះបណ្តាលសម្រាប់ស្ត្រីក្នុងការបង្ការ និងព្យាបាលជំងឺសត្វកម្រិតស្រាល | នឹងត្រូវបានកំណត់ | នឹងត្រូវបានកំណត់ |
| | ៦.ភាគរយស្ត្រី និងបុរស វ័យក្មេងដែលបានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលភាពជាសហគ្រិន ស្តីពីសហគ្រាសកសិ-ពាណិជ្ជកម្ម ព្រៃឈើ និងជលផល (វារីវប្បកម្ម) | នឹងត្រូវបានកំណត់ | នឹងត្រូវបានកំណត់ |
| | ៧.ភាគរយស្ត្រី និងបុរស ដែលមានលទ្ធភាពទទួលបាន និងប្រើប្រាស់ព័ត៌មានបច្ចេកវិទ្យា សម្រាប់ផលិតកម្មកសិកម្ម និងទីផ្សារកសិកម្ម | នឹងត្រូវបានកំណត់ | ឯកសារជាតិស្តីពីយេនឌ័រនៃគ្រួសារប្រកបរបរកសិកម្ម (២០១០) |

| | | | |
|---|---|---|---|
| | ៨.ភាគរយស្ត្រី និងបុរស ដែលបម្រើការងារជាកម្មករជំនាញ និងពាក់កណ្តាលជំនាញ ក្នុងផលិតកម្មកសិកម្ម ការងារក្រោយប្រមូលផល និងការកែច្នៃ | នឹងត្រូវបានកំណត់ | ឯកសារជាតិស្តីពីយេនឌ័រ នៃគ្រួសារប្រកបរបរកសិកម្ម (២០១០) |
| | ៩. សេវាកម្មផ្សព្វផ្សាយឆ្លើយតបនឹងយេនឌ័រ ដែលដោះស្រាយភាពលំអៀងយេនឌ័រ ជាលក្ខណៈប្រព័ន្ធ ដោយយកចិត្តទុកដាក់ទៅលើបញ្ហាស្ត្រីដូចជា អក្ខរភាព បញ្ហាប្រឈមលើពេលវេលា និងការដើរហើរ។ | នឹងត្រូវបានកំណត់ | នឹងត្រូវបានកំណត់ |
| | ១០.ភាគរយស្ត្រី និងបុរស ដែលមានការយល់ដឹងកាន់តែប្រសើរអំពីការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ | | នឹងត្រូវបានកំណត់ |
| | ១១.ភាគរយស្ត្រី និងបុរស ដែលពឹងផ្អែកទៅលើការប្រើប្រាស់ជីវម៉ាសសម្រាប់ចម្អិនអាហារ និងការកែច្នៃផលិតផលកសិកម្មមានការថយចុះ | | នឹងត្រូវបានកំណត់ |
| | ១២.ភាគរយស្ត្រី និងបុរស មានការយល់ដឹងប្រសើរឡើងពីការដាំដុះកៅស៊ូ ថែទាំ ចៀរជ័រ និងកែច្នៃ ផលិតផលកៅស៊ូ | | មិនមាននៅឡើយ |
| ៣.ស្ត្រីមានបណ្តាញកាន់តែរឹងមាំជាមួយនឹងទីផ្សារបែបប្រពៃណី និងទីផ្សារថ្មីៗ ។ | ១.ភាគរយស្ត្រី និងបុរស ជាសមាជិកក្នុងក្រុមទីផ្សារអ្នកផលិត សហគមន៍កសិកម្ម សហគមន៍នេសាទ និងសហគមន៍ព្រៃឈើ | នឹងត្រូវបានកំណត់ | នឹងត្រូវបានកំណត់ |
| | ២.ភាគរយស្ត្រី និងបុរស ក្នុងតួនាទីជាអ្នកដឹកនាំនៃក្រុមទីផ្សារអ្នកផលិត និងសហគមន៍កសិកម្ម សហគមន៍កសិកម្ម សហគមន៍នេសាទ និងសហគមន៍ព្រៃឈើ | នឹងត្រូវបានកំណត់ | នឹងត្រូវបានកំណត់ |
| | ៣.ភាគរយស្ត្រី និងបុរស ដែលបានបង្កើតទំនាក់ទំនងជាមួយឈ្មួញលំដាប់ខ្ពស់នៅថ្នាក់ស្រុក ខេត្ត និងជាតិ | នឹងត្រូវបានកំណត់ | នឹងត្រូវបានកំណត់ |
| | ៤.ភាគរយស្ត្រី និងបុរស ជាបុគ្គល ឬក្រុមទីផ្សារអ្នកផលិត ដែលផ្សាភ្ជាប់នឹងវិស័យទេសចរណ៍ និងទីផ្សារលក់ចំណីអាហារ នៅថ្នាក់ស្រុក ខេត្ត និងជាតិ | នឹងត្រូវបានកំណត់ | នឹងត្រូវបានកំណត់ |
| | ៥.ចំនួនកិច្ចព្រមព្រៀងលើការបញ្ជាទិញ ដែលចរចារដោយស្ត្រី និងបុរស ដោយធ្វើឡើងជាលក្ខណៈឯកជន ឬជាក្រុមទីផ្សារអ្នកផលិត | នឹងត្រូវបានកំណត់ | នឹងត្រូវបានកំណត់ |

| | | | |
|---|---|---|---|
| | ៦.ភាគរយស្ត្រី និងបុរស ដែលមានទទួលបានព័ត៌មានទីផ្សារ និងពិព័ណ៌នៅថ្នាក់មូលដ្ឋាន ខេត្ត និងជាតិ | នឹងត្រូវបានកំណត់ | នឹងត្រូវបានកំណត់ |
| | ៧.ភាគរយនៃស្ត្រី និងបុរស ជាអ្នកផលិតដែលបានចូលរួមក្នុងទីផ្សារ និងការតាំងពិព័ណ៌កសិករនៅថ្នាក់ខេត្ត និងជាតិ | នឹងត្រូវបានកំណត់ | នឹងត្រូវបានកំណត់ |
| | ៨. ភាគរយស្ត្រី និងបុរស ជាកសិករដែលមានលទ្ធភាពចូលរួមក្នុងទីផ្សារនាំចេញ ពិសេសសម្រាប់ផលិតផលដែលមានតម្លៃខ្ពស់ និងផលិតផលដែលមានស្លាកសញ្ញាក្នុងទីផ្សារ (brand-marketed products) ដូចជា ការធ្វើជំនួញដោយស្មើភាព និងផលិតផលសរីរាង្គដែលមានការទទួលស្គាល់ | នឹងត្រូវបានកំណត់ | នឹងត្រូវបានកំណត់ |
| **គោលបំណងទី២៖ ពង្រឹងសមត្ថភាព ធនធាន និងការប្តេជ្ញាចិត្តរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធានានូវប្រសិទ្ធិភាពនៃការបញ្ជ្រាបយេនឌ័រទៅក្នុងវិស័យកសិកម្ម** | | | |
| **លទ្ធផល** | **សូចនាករណ** | **មធ្យោបាយផ្ទៀងផ្ទាត់** | **ទិន្នន័យគោល** |
| ១.តម្រូវការ និងកង្វល់របស់ស្ត្រីក៏ដូចជាបុរសត្រូវបានដាក់បញ្ចូលទៅក្នុងគ្រប់គោលនយោបាយ លិខិតបទដ្ឋាន និងក្របខ័ណ្ឌច្បាប់ | ១. ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់ផលិតកម្មសត្វ (២០១៥-២០២៥) មានការឆ្លើយតបទៅនឹងយេនឌ័រ | - ឯកសារផែនការយុទ្ធសាស្ត្រផលិតកម្មសត្វ | |
| | ២. ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល (២០១៥-២០២៥) មានការឆ្លើយតបទៅនឹងយេនឌ័រ | - ឯកសារផែនការយុទ្ធសាស្ត្រវិស័យជលផល | |
| | ៣. ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម (២០១៥-២០២៥) មានការឆ្លើយតបទៅនឹងយេនឌ័រ | - ឯកសារផែនការយុទ្ធសាស្ត្រវិស័យកសិកម្ម | |
| | ៤. ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យព្រៃឈើ (២០១៥-២០២៥) មានការឆ្លើយតបទៅនឹងយេនឌ័រ | - ឯកសារផែនការយុទ្ធសាស្ត្រវិស័យព្រៃឈើ | |
| | ៥. គោលនយោបាយផ្សព្វផ្សាយកសិកម្ម មានការឆ្លើយតបទៅនឹងយេនឌ័រ | - គោលនយោបាយផ្សព្វផ្សាយកសិកម្ម | |

| | | | |
|---|---|---|---|
| | ៦. គោលនយោបាយអភិវឌ្ឍន៍សមត្ថភាព និងធនធានមនុស្សរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានការឆ្លើយតបទៅនឹងយេនឌ័រ | - ឯកសារគោលនយោបាយអភិវឌ្ឍន៍សមត្ថភាព និងធនធានមនុស្ស | |
| | ៧. ក្របខ័ណ្ឌផែនការយុទ្ធសាស្រ្តសម្រាប់វិស័យកៅស៊ូ (២០១៦-២០២៥) មានការឆ្លើយតបទៅនឹងយេនឌ័រ | -ឯកសារផែនការយុទ្ធសាស្រ្តវិស័យ កៅស៊ូ | |
| | ៨. បញ្ហាយេនឌ័រត្រូវបានដាក់បញ្ចូល ទៅក្នុងកម្មវិធីសិក្សារបស់គ្រឹះស្ថានអប់រំកសិកម្ម | - កម្មវិធីសិក្សា | |
| | ៩. បញ្ហាយេនឌ័រត្រូវបានដាក់បញ្ចូល ទៅក្នុងគោលនយោបាយវាយតម្លៃហានិភ័យ និងការគ្រប់គ្រងធនធានធម្មជាតិ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬអន្តរក្រសួង | - ឯកសារស្តីអំពីហានិភ័យ និងការគ្រប់គ្រងធនធានធម្មជាតិ | |
| | ១០.ផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ (២០១៦-២០២០) ក្នុងវិស័យកសិកម្ម | - ឯកសារផ្ទៃក្នុង-របាយការណ៍របស់ក្រុមការងារយេនឌ័រ និងកុមារ | |
| ២.បញ្ហាយេនឌ័រត្រូវបានបញ្ចូលទៅក្នុងការរៀបចំផែនការ ការអនុវត្ត ការតាមដាន និង ការវាយតម្លៃលើគ្រប់សកម្មភាព សេវាកម្ម បច្ចេកទេស គម្រោង កម្មវិធី និងថវិកា | ១. ការវិភាគយេនឌ័រត្រូវបានធ្វើឡើងតាមដំណាក់កាលនីមួយៗ ក្នុងការធ្វើផែនការ និងអនុវត្តគ្រប់សកម្មភាព និងកម្មវិធី របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | - របាយការណ៍របស់ក្រុមការងារយេនឌ័រ និងកុមារ | |
| | ២. ទិន្នន័យ និងគោលដៅដែលបែងចែកតាមភេទត្រូវបានដាក់បញ្ចូលទៅក្នុងផែនការ ការត្រួតពិនិត្យ និងវាយតម្លៃគ្រប់សកម្មភាព និងកម្មវិធីរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | - របាយការណ៍របស់ក្រុមការងារយេនឌ័រ និងកុមារ<br>-របាយការណ៍ផ្ទៃក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ<br>- នាយកដ្ឋានផែនការ និងស្ថិតិ | |
| | ៣. របាយការណ៍របស់នាយកដ្ឋាន រដ្ឋបាល និងកម្មវិធីទាំងអស់ មានព័ត៌មានយេនឌ័រពេញលេញ | - របាយការណ៍ផ្ទៃក្នុងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | |

| | | | |
|---|---|---|---|
| ៣.ក្រុមការងារយេនឌ័រ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសមត្ថភាព ជំនាញច្បាស់លាស់ និង ធនធាន សម្រាប់អនុវត្ត ការងារ ការតស៊ូមតិ ការកសាង ចំណេះដឹង ភាពជាដៃគូ ជំនួយការ បច្ចេកទេស និងតួនាទី ត្រួតពិនិត្យ។ | ១. ចំនួនសកម្មភាពផ្តួចផ្តើមក្នុងការអភិវឌ្ឍន៍សមត្ថភាពសមាជិកក្រុមការងារយេនឌ័រ និងកុមារ និងជនបង្គោលនៅគ្រប់កម្រិត (ការបង្រៀន ការហ្វឹកហាត់ និងការរៀនសូត្រតាមរយៈការងារ) ជាពិសេសទៅលើបញ្ហា ដែលកើតឡើងថ្មីៗ ដូចជាការប្រែប្រួលអាកាសធាតុ | - របាយការណ៍ប្រចាំឆ្នាំ និងផែនការសកម្មភាព របស់ក្រុមការងារ យេនឌ័រ និងកុមារ | |
| | ២. ចំនួនវគ្គបណ្តុះបណ្តាល ដំណើរផ្លាស់ប្តូរបទពិសោធន៍ ទស្សនៈកិច្ចសិក្សា និងវគ្គសិក្សាដែលមានការទទួលស្គាល់ (ក្រុមការងារយេនឌ័រ និងកុមារ និងជនបង្គោលនៅគ្រប់កម្រិត) ជាពិសេសទៅលើបញ្ហា ដែលកើតឡើងថ្មីៗ ដូចជាការប្រែប្រួលអាកាសធាតុ | - របាយការណ៍ប្រចាំឆ្នាំ និងផែនការសកម្មភាព របស់ក្រុមការងារ យេនឌ័រ និងកុមារ | |
| | ៣. ចំនួនសមាជិកក្រុមការងារយេនឌ័រ និងកុមារដែលបានចូលរួម និងធ្វើបទបង្ហាញជាផ្លូវការ ក្នុងសិក្ខាសាលាទាក់ទងនឹងគោលនយោបាយ ជាពិសេសទៅលើបញ្ហាដែលកើតឡើងថ្មីៗ ដូចជាការប្រែប្រួលអាកាសធាតុ | - របាយការណ៍ប្រចាំឆ្នាំ និងផែនការសកម្មភាព របស់ក្រុមការងារ យេនឌ័រ និងកុមារ | |
| | ៤. ចំនួនបទបង្ហាញ របស់ក្រុមការងារយេនឌ័រ និងកុមារ ក្នុងក្រុមការងារបច្ចេកទេសដែលពាក់ព័ន្ធ ជាពិសេសទៅលើបញ្ហាដែលកើតឡើងថ្មីៗ ដូចជាការប្រែប្រួលអាកាសធាតុ | - របាយការណ៍ប្រចាំឆ្នាំ និងផែនការសកម្មភាព របស់ក្រុមការងារ យេនឌ័រ និងកុមារ<br>- ឯកសារសម្រាប់ធ្វើបទបង្ហាញ | |
| | ៥. ផែនការសកម្មភាព របស់ក្រុមការងារយេនឌ័រ និងកុមារបានបង្កើត និងទទួលបានការគាំទ្រថវិកាប្រចាំឆ្នាំគ្រប់គ្រាន់ | របាយណ៍ការផ្ទៃក្នុង របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | |
| | ៦. ចំនួន សកម្មភាពផ្តួចផ្តើមភាពជាដៃគូជាមួយនឹងក្រសួងកិច្ចការនារី អង្គការអភិវឌ្ឍន៍ដែលពាក់ព័ន្ធ និងអង្គការសិទ្ធិស្ត្រីក្នុងការស្វែងរកការគាំទ្រមតិ ការគាំទ្របច្ចេកទេស ការអភិវឌ្ឍន៍សមត្ថភាព ការតាមដាន និងការវាយតម្លៃ និងការស្រាវជ្រាវ | - របាយការណ៍ប្រចាំឆ្នាំ របស់ក្រុមការងារ យេនឌ័រ និងកុមារ<br>- របាយការណ៍ផ្ទៃក្នុង របស់ក្រសួងកិច្ចការនារី | |

| | | | |
|---|---|---|---|
| | ៧. ចំនួនឯកសារបោះពុម្ពទាក់ទងទៅនឹងយេនឌ័រ (គោលការណ៍ណែនាំ ឧបករណ៍បង្រៀន ការស្រាវជ្រាវ ករណីសិក្សានិងឯកសារបណ្តុះបណ្តាល របាយការណ៍សេចក្តីសង្ខេបបច្ចេកទេស និងឯកសាររបស់ផ្សព្វផ្សាយនានា) | -ឯកសារបោះពុម្ព និង ឯកសារផ្សេងៗ | |
| | ៨.ចំនួនសិក្ខាសាលាពិគ្រោះយោបល់លើគោលនយោបាយស្តីពីបញ្ហាយេនឌ័រ ក្នុងវិស័យកសិកម្ម | - របាយការណ៍ប្រចាំឆ្នាំរបស់ ក្រុមការងារយេនឌ័រ និងកុមារ | |
| **គោលបំណងទី៣៖** បង្កើនភាពជាតំណាង និងការចូលរួមស្មើភាពគ្នាទាំងបុរស និងស្ត្រីក្នុងវិស័យកសិកម្ម | | | |
| **លទ្ធផល** | **សូចនាករណ** | **មធ្យោបាយ ផ្ទៀងផ្ទាត់** | **ទិន្នន័យគោល** |
| ១.វត្តមាន និងឥទ្ធិពលរបស់ស្ត្រីក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានការកើនឡើង | ១. ចំនួនស្ត្រីនៅក្នុងតំណែងជាថ្នាក់ដឹកនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានការកើនឡើងជារៀងរាល់ឆ្នាំ (នៅថ្នាក់ជាតិ ខេត្ត និងស្រុក) | - របាយការណ៍ធនធានមនុស្សរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ទិន្នន័យបុគ្គលិក ឆ្នាំ ២០១៦ |
| | ២. ភាគរយស្ត្រីនៅក្នុងតួនាទីគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានការកើនឡើងជារៀងរាល់ឆ្នាំ (នៅថ្នាក់ជាតិ ខេត្ត និងស្រុក) | - របាយការណ៍ធនធានមនុស្សរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ទិន្នន័យបុគ្គលិក ឆ្នាំ ២០១៦ |
| | ៣. ភាគរយស្ត្រីដែលមានតួនាទីជាមន្ត្រីបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានការកើនឡើងជារៀងរាល់ឆ្នាំ (នៅថ្នាក់ជាតិ ខេត្ត និងស្រុក) | - របាយការណ៍ធនធានមនុស្សរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ទិន្នន័យបុគ្គលិក ឆ្នាំ ២០១៦ |

| | | | |
|---|---|---|---|
| | ៤. ភាគរយមន្ត្រីផ្សព្វផ្សាយជាស្ត្រីរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានការកើនឡើង | - របាយការណ៍ធនធានមនុស្សរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ទិន្នន័យបុគ្គលិក ឆ្នាំ ២០១៦ |
| ២.វត្តមាន និងឥទ្ធិពលរបស់ស្ត្រី ក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងក្រុមគ្រប់គ្រងធនធានធម្មជាតិ និងកសិកម្មក្នុងសហគមន៍មានការកើនឡើង | ១. ភាគរយស្ត្រី និងបុរសដែលចូលរួមក្នុងក្រុម សហគមន៍ ឬភូមិ (សមាគមកសិករ ក្រុមអ្នកប្រើប្រាស់ទឹក សហគមន៍នេសាទ និងសហគមន៍ព្រៃឈើ | - របាយការណ៍ផ្ទៃក្នុងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ទិន្នន័យផ្ទៃក្នុង របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអនុវិស័យ ឆ្នាំ ២០១៦ |
| | ២. ភាគរយរបស់ស្ត្រី និងបុរសដែលមានតួនាទីជាអ្នកគ្រប់គ្រងសហគមន៍កសិករ សហគមន៍នេសាទ និងសហគមន៍ព្រៃឈើ | របាយការណ៍ផ្ទៃក្នុងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ទិន្នន័យផ្ទៃក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអនុវិស័យ ឆ្នាំ ២០១៦ |
| ៣.ស្ត្រីកាន់តែមានលទ្ធភាពទទួលបានឱកាសអភិវឌ្ឍន៍ជំនាញ និងការសិក្សា ដើម្បីគាំទ្រដល់ការចូលរួមរបស់ពួកគាត់ក្នុងវិស័យកសិកម្ម រួមមានផលិតកម្មដំណាំ ការចិញ្ចឹមសត្វ ជលផល ព្រៃឈើ និងកៅស៊ូ។ | ១. ភាគរយស្ត្រី និងបុរសដែលទទួលបានអាហារូបករណ៍ | របាយការណ៍ធនធានមនុស្សរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | របាយការណ៍ធនធានមនុស្សរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១៦ |
| | ២. ភាគរយស្ត្រី និងបុរសដែលមានលទ្ធភាពទទួលបានឱកាសអភិវឌ្ឍន៍ការគ្រប់គ្រង និងបច្ចេកទេស | របាយការណ៍ធនធានមនុស្សរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | របាយការណ៍ធនធានមនុស្សរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១៦ |
| | ៣. ភាគរយស្ត្រី និងបុរសដែលមានតួនាទីជាមន្ត្រីបច្ចេកទេស និងជាមន្ត្រីជាន់ខ្ពស់នៅក្នុងស្ថាប័នបណ្តុះបណ្តាល | របាយការណ៍ធនធានមនុស្សរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | របាយការណ៍ន.បុគ្គលិកនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១៦ |

| | | | |
|---|---|---|---|
| | ៤. ចំនួនវគ្គបណ្តុះបណ្តាល និងឱកាសអភិវឌ្ឍន៍ជំនាញ សម្រាប់មន្ត្រីជាស្ត្រី នៅគ្រប់កម្រិត របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | - របាយការណ៍ប្រចាំឆ្នាំរបស់ក្រុមការងារយេនឌ័រ និងកុមារ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- របាយការណ៍ផ្ទៃក្នុងរបស់នាយកដ្ឋានក្រោមឱវាទ | របាយការណ៍ផ្ទៃក្នុងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១៦ |
| | ៥. ភាគរយស្ត្រី និងបុរសចូលរួមក្នុង និងទទួលបានផលប្រយោជន៍ពីសកម្មភាពបន្សាំ និង ឬ កាត់បន្ថយបម្រែបម្រួលអាកាសធាតុ | - របាយការណ៍ប្រចាំឆ្នាំរបស់ក្រុមការងារយេនឌ័រ និងកុមារ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- របាយការណ៍ផ្ទៃក្នុងរបស់នាយកដ្ឋានក្រោមឱវាទ | នឹងត្រូវបានកំណត់ |
| | ៦. ភាគរយសិស្សស្រីចុះឈ្មោះចូលរៀននៅក្នុងគ្រឹះស្ថានអប់រំកសិកម្ម កើនឡើងជារៀងរាល់ឆ្នាំ (បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត) | ទិន្នន័យរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ទិន្នន័យរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០១៦ |